# ការសំភាសន៍របស់អ្នកមីង សុខ សូផាត់

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ សុខ សូផាត់

## ការសង្ខេបរបស់អ្នកមីង សុខ សូផាត់

អ្នកមីង សុខ សូផាត់ គាត់មានអាយុ ៥៦ឆ្នាំ ក្នុងឆ្នាំ ២០១៨។អ្នកមីង សុខ សូផាត់ ភេទស្រីអ្នកមីង សុខ សូផាត់ មានកូនចំនួន ៥ នាក់។អ្នកមីង សុខ សូផាត់ បានរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងឆ្នាំ ១៩៨៤។អ្នកមីង សុខ សូផាត់ ភូមិ ឧញ៉ាតី កោះឧកញ៉ាតី ខេត្ត កណ្តាលអ្នកមីង សុខ សូផាត់ ភូមិ មានទីលំនៅនាពេលបច្ចុប្បន្ននៅ ភូមិ ឧកញ៉ាតី កោះ ឧកញ៉ាតី ខេត្ត កណ្តាល។

កៈ
ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍អ្នកមីងអំពីពង្សប្រវត្តិតតើអ្នកមីងអាយអនុញ្ញាត្តិអោយសំភាសន៍អ្នកមីងពង្សប្រវត្តិអ្នកមីងបានដែលទេ???

ខៈ
ចាសបានហើយសំរាប់កន្លែងណាដែលខ្ញុំឆ្លើយបានខ្ញុំនឹងឆ្លើយចឹងហាសហើយសំរាប់កន្លែងណាដែលខ្ញុំឆ្លើយមិនបានគឺខ្ញុំនឹងមិនឆ្លើយចឹងទៅចាសហើយយើងនឹងហូសចឹងទៅហេហេហេហេ ៕

កៈ បាទអត់អីទេអ្នកមីងចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍លោកយាយគឺជាថ្ងៃទី០៩ ខែ ០៦ (មិថុនា)
ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះ សុខ សូផាត់ ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះអ្នកមីងបាទេ???

ខៈ ចាសសំរាប់ឈ្មោះរបស់ខ្ញុំនឹងគឺខ្ញុំមានឈ្មោះថា សុខ សូផាត់ចាស៕

កៈ
បាទហើយចឹងសំណួរដំបូងដែលខ្ញុំចង់អ្នកមីងហាសថាតើអ្នកមីងឈ្មោះពេញរបស់អ្នកមីងទាំងត្រកូលរបស់អ្នកមីងមាឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ឈ្មោះពេញរបស់ខ្ញុំនឹងគឺឈ្មោះ សុខ សូផាត់តែម្តងហាសចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានឈ្មោះហៅក្រៅដែលរឺទេអ្នកមីង???

ខៈ ចាសអត់មានទេគឺមានតែឈ្មោះ សុខ ស្វផាត់នឹងចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងឆ្នាំនឹងថាតើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខៈ ចាសសំរាប់ឆ្នាំនឹងគឺខ្ញុំមានអាយុ ៥៦ ឆ្នាំហើយចាស៕

កៈ បាទហើយចឹងសំរាប់អ្នកមីងមានទីកន្លែងកំណើតនៅទីកន្លែងណាដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមានទីកន្លែងកំណើតនៅទីកន្លែងនឹងតែម្តងហាសចាស៕

កៈ បាទហើយសំរាប់អ្នកមីងរស់នៅភូមិអ្វីស្រុកអ្វីខេត្តអ្វីដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ខ្ញុំនឹងគឺរស់នៅកោះឧកញ្ញាតីស្រុកខ្សាយកណ្តាល់ហើយនឹងខេត្តកណ្តាលចាស
៕

កៈ បាទហើយចឹងសំរាប់អ្នកមីងថាតើអ្នកមីងមានកូនចំនួនប៉ុន្មាននាក់ដែលអ្នកមីង???

ខៈ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមានកូនចំនួន ៥ នាក់ចាស៕

កៈ បាទហើយចឹងសំរាប់មានបានចាំឈ្មោះរបស់គាត់ទាំងអស់ដែលរឺទេអ្នកមីង???

ខៈ ចាសខ្ញុំចាំ៕

កៈ បាទហើយចឹងសំរាប់អាចរាប់ឈ្មោះរបស់គាត់ម្តងម្នាក់ម្តងម្នាក់បានដែលរឺទេអ្នកមីង???

ខៈ ចាសសំរាប់កូនរបស់ខ្ញុំទី១នឹងគឺគាត់មានឈ្មោះថា ម៉ុម គីម សេង
ហើយសំរាប់កូនរបស់ខ្ញុំទី២នឹងគឺគាត់មានឈ្មោះថាម៉ុម សុខ ចំរើន
ហើយសំរាប់កូនរបស់ខ្ញុំទី៣នឹងគឺគាត់មានឈ្មោះថា ម៉ុម សុភា
ហើយសំរាប់កូនរបស់ខ្ញុំទី៤នឹងគឺគាត់មានឈ្មោះថា ម៉ុម សុភណ្ឌ័
ហើយសំរាប់កូនរបស់ខ្ញុំទី៥នឹងគឺគាត់មានឈ្មោះថា ម៉ុម ចាន់នី ចាស៕

កៈ
បាទហើយចឹងសំរាប់សព្វថ្ងៃនឹងថាតើពួកគាត់នៅសិក្សារឺក៏នៅធ្វើការងារដែលទៅអ្នកមីង??
?

ខៈ
ចាសនិយាយទៅគឺពួកគាត់បាឈប់រៀនអស់ហើយហើយពួកគាត់នឹងនៅធ្វើការងារចឹងហា

សចាសហើយសំរាប់ក្រៅពីនឹងគឺគេបានមានប្តីហើយនឹងប្រពន្ធអស់ហើយចឹងហាសគឺនៅតែអាអ្នកដែលកូនពៅហាសទី៥ចាស៕

កៈ បាទហើយចឹងនៅពេលដែលពួកគាត់បានរៀបអាពាហ៍ពិពាហ៍ហើយចឹងថាតើពួកគាត់បានរស់នៅជាមួយនឹងគ្នារឺជុំគ្នារឺក៏នៅឆ្ងាយរឺក៏យ៉ាងមិចដែលអ្នកមីង???

ខៈ ចាសសំរាប់ពួកនៅពេលដែលពួកគាត់បានរៀបអាពាហ៍ពិពាហ៍ហើយចឹងគឺសំរាប់ប្រុសនឹងគឺគេបានរស់ខាងស្រីចឹងទៅហើយសំរាប់ខាងស្រីនឹងរៀបអាពាហ៍ពិពាហ៍ហើយចឹងគឺនៅខាងប្រុសចឹងទៅហើយសំរាប់ខាងប្រុសនឹងគឺគេបានរស់នៅខាងប្រពន្ធរបស់គេចឹងទៅចាស៕

កៈ បាទហើយចឹងសំរាប់ស្វាមីរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែលទៅអ្នកមីង???

ខៈ ចាសសំរាប់ស្វាមីរបស់ខ្ញុំនឹងគឺគាត់មានឈ្មោះថា មែល ម៉ុម ៕

កៈ បាទសំរាប់លោកពូគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខៈ សំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់មានអាយុ ៥៧ ឆ្នាំ ហើយចាស៕

កៈ បាទអរចឹងបានន័យថាអ្នកមីងបងប្តីរបស់អ្នកមីងមែនដែលទេអ្នកមីង???

ខៈ ចាសអត់ទេប្តីរបស់ខ្ញុំនឹងគឺគាត់បងខ្ញុំនោះទេចាសពីព្រោះអីនឹងប្តីរបស់ខ្ញុំនឹង ៥៧ ហើយសំរាប់ខ្ញុំនឹង ៥៦ នឹងចាស៕

កៈ បាទបាទហើយសំរាប់លោកពូគាត់បានប្រកបមុខរបបអ្វីដែលទៅអ្នកមីង???

ខៈ
ចាសសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់ជាជាងកប៉ាល់ចឹងហាសចាសហើយសំរាប់ប្តីរបស់ខ្ញុំនឹងគឺគាត់ពីមុននឹងគឺគាត់ធ្វើការងារជាទាហ៊ានចឹងហាសចាសហើយគាត់បានធ្វើជាទាហ៊ាននឹងបានផ្កាយ៣រឺក៏ផ្កាយ៤ហាសដែលគាត់ធ្វើជាទាហ៊ានហាសចាសហើយនៅពេលដែលគាត់បានធ្វើការនឹងគឺគាត់បានដើលជាន់មីនហើយគាត់បានដាច់ជើង៕

កៈ
បាទហើយចឹងសំរាប់ស្រុកកំណើតរបស់លោកពូគាត់មានទីកន្លែងកំណើតនឹងនៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសសំរាប់ស្រុកកំណើតរបស់គាត់នឹងគឺគាត់រស់ភូមិធំហាសចាសស្រុកពញ្ញាពងភូមិពញ្ញាពងខេត្តកណ្តាលចាសហើយសំរាប់លូវនឹងគឺគេបានកាត់ចូលទៅក្រុងវិញហើយចឹងហាសចាសនិយាយទៅគឺគេទើបតែកាត់ដែលចឹងហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងហើយនឹងលោកពូបានរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងឆ្នាំណាដែលទៅអ្នកមីង???

ខ៖ ចាសនៅពេលដែលខ្ញុំអ្នកមីងបានរៀបអាពាហ៍ពិពាហ៍នឹងនៅក្នុងឆ្នាំ ១៩៨៥ ហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលបានរៀបអាពាហ៍ពិពាហ៍នឹងថាតើអ្នកមីងស្រឡាញ់ដោយស្មាក់ចិត្តរឺក៏មានឪពុកហើយនឹងម្តាយរបស់អ្នកមីងគាត់បង្ខំអ្នកមីងដែលទៅអ្នកមីង???

ខ៖
ចាសនៅក្នុងជំនាន់របស់ខ្ញុំនឹងហាសនៅពេលដែលបានរៀបអាពាហ៍ពិពាហ៍គឺគ្មាននាក់ណាបានបង្ខំយើងនោះទេចាសហើយប្រសិនជាគេបានចូលមកដល់ម្តាយហើយនឹងឪពុករបស់យើងនឹងគឺមិនអីនោះទេចាសកាល់នៅក្នុងជំនាន់នឹងហាសហើយមិនដូចមកជំនាន់លូវនឹងនោះទេចាសហើយនៅពេលដែលយើងគិតគូរហើយនឹងទុក្ខដាក់អីនឹងគឺនៅលើយើងហាសចាសហេហេហេ៕

ក៖
បាទហើយចឹងបានន័យថាអ្នកមីងស្រឡាញ់លោកពូដោយស្មាក់ចិត្តមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំស្រឡាញ់ដោយស្មាក់ចិត្តហើយសំរាប់ម្តាយហើយនឹងឪពុករបស់ខ្ញុំនឹងក៏ពេញចិត្តហើយយើងនឹងក៏ជាកូននឹងក៏បានគោរពឪពុកហើយនឹងម្តាយដែលគាត់ជាអ្នកមានគុណទៅតាមម្តាយរបស់យើងចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរៀនអាពាហ៍ពិពាហ៍ជាមួយនឹងលោកពូហើយចឹងហើយសំរាប់អ្នកមីងបានរៀនអាពាហ៍ពិពាហ៍ជាមួយនឹងលោកពូនៅក្នុងឆ្នាំ ១៩៨៥ ហើយអ្នកមីងមានកូនចំនួន ៥ នាក់ហើយចឹងសព្វថ្ងៃនឹងថាតើអ្នកមីងមានចៅនឹងចំនួនប៉ុន្មាននាក់ដែលទៅអ្នកមីង???

ខ៖ ចាសប្រសិនជានិយាយទៅគឺចៅរបស់ខ្ញុំនឹងគឺមានចំនួន ៨ នាក់ ហើយប្រសិនជារាប់ទាំងចៅនៅក្នុងពោះទៀតនឹងគឺ ៩ នាក់ហើយក្មួយហេហេហេហេ៕

ក៖ បាទហើយចឹងចៅរបស់អ្នកមីងដែលគាត់ធំជាងគេនឹងគាត់មានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង???

ខ៖ ចាសសំរាប់ចៅធំជាងរបស់ខ្ញុំនឹងគឺគាត់មានអាយុ ១៤ ឆ្នាំ ហើយចាសហើយគាត់បានរៀនបានថ្នាក់ទី ៤ ហើយចឹងហាសចាស៕

ក៖ បាទហើយចឹងល្វនឹងគាត់កំពុងតែរៀនមែនដែលទេអ្នកមីងហើយសំរាប់ចៅតូចតូចនឹងគឺគាត់បាននៅផ្ទះមែនដែលទេអ្នកមីងហេហេហេហេបាទហើយចឹងសំរាប់អ្នកមីងចាំឈ្មោះចៅរបស់អ្នកមីងទាំង ៩ នាក់ដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយទៅកូនអាបងនឹងគឺខ្ញុំអត់ចាំចំនួន ២ នាក់ហើយសំរាប់ក្រៅពីនឹងគឺខ្ញុំចាំទាំងអស់ចាសនិយាយទៅគឺខ្ញុំមិនបានចាំចៅ២នាក់ពីព្រោះអីនឹងគឺវានឹងបានបែកបាក់នឹងគ្នាចឹងហាសចាស៕

ក៖ បាទហើយចឹងសំរាប់អ្នកមីងអាចរាប់ឈ្មោះចៅរបស់អ្នកមីងបានដែលរឺទេអ្នកមីង???

ខ៖ ចាសមានអីចាសសំរាប់ចៅរបស់ខ្ញុំនឹងទី១គាត់មានឈ្មោះថា ចាន់ ថេន
ហើយសំរាប់ចៅរបស់ខ្ញុំនឹងទី២គាត់មានឈ្មោះថា រក្សា
សំរាប់ចៅរបស់ខ្ញុំនឹងទី៣គាត់មានឈ្មោះថា រឿន រ៉ានី
សំរាប់ចៅរបស់ខ្ញុំនឹងទី៤គាត់មានឈ្មោះថា ហង្ស លីណា
សំរាប់ចៅរបស់ខ្ញុំនឹងទី៥គាត់មានឈ្មោះថា ហង្ស លីដា
សំរាប់ចៅរបស់ខ្ញុំនឹងទី៦គាត់មានឈ្មោះថា ហង្ស ដាលីន
ហើយសំរាប់បងកូនបងដែលនៅក្នុងពោះនឹងគឺគេមានឈ្មោះថា សេង ស្រី ពេជ្រ
ហាសចាសហើយសរុបទាំងអស់ទៅ ៧ នាក់ហើយសំរាប់២នាក់ទៀតនឹងគឺខ្ញុំមិនបានចាំឈ្មោះចឹងហាសចាសហើយសំរាប់ប្រុសប្រុសក្រោយនឹងគឺខ្ញុំបានភ្លេចហើយចឹងហាសចឹងហើយរាប់ទៅបានតែ ៨ នាក់នោះទេចាសហើយសំរាប់ប្រុសប្រុសក្រោយនឹងគឺខ្ញុំបានភ្លេចឈ្មោះរបសពួកគេចឹងទៅហើយ ៩ នាក់នឹងទាំងនៅក្នុងពោះម្នាក់នោះទេចឹងហាសហេហេហេហេចាស៕

កៈ បាទហើយចឹងសំរាប់ចៅរបស់អ្នកមីងមានចំនួន ៩ នាក់ បាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងសំណួរខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពេលដែលអ្នកមីងនៅកុមារនឹងថាតើអ្នកមីងមានរៀនរឺក៏បានសិក្សាដែរឬរីទេអ្នកមីង??

ខៈ

ចាសជំនាន់មុននឹងគឺខ្ញុំបានរៀនដែលតាហើយសំរាប់ការរៀនឹងពីដើមនឹងគឺគេបានមិនហៅថ្នាក់ទី១ថ្នាក់ទី២ចឹងនោះទេចាសហើយសំរាប់ចូលដំបូងនឹងគឺចូលរៀនថ្នាក់ ១២ ហើយសំរាប់ថ្នាក់ ១២ពីមុននឹងគឺស្មើនឹងថ្នាក់ទី១សព្វថ្ងៃនឹងហាសចាសដល់ពេលហើយនឹងឡើងបានថ្នាក់ ទី ១១ ដល់ថ្នាក់ ១០ ដល់ថ្នាក់ ៩ ហើយនឹងដល់ថ្នាក់ ទី៨ចឹងហាសាចាសក្មួយហើយប្រសិនជាមកដល់លូវនឹងគឺរៀនបានថ្នាក់ ៦រឺក៏ថ្នាក់៧ហើយចឹងហាសចាសហើយសំរាប់ជំនាន់ពីដើមនឹងគឺខ្ញុំនឹងមិនបានរៀនអគ្លេសនោះទេគឺគេមានតែភាសាបាំរាំងនោះទេចាសហេហេហេនឹងសំរាប់ជនាន់នឹងហាសនឹងសំរាប់នៅជំនាន់នៅក្មេងហើយគឺជាជំនាន់លុនណលហាសចាស៕

កៈ

បាទហើយសំរាប់អ្នកមីងនៅពេលដែលអ្នកមីងរៀននឹងថាតើអ្នកមីងគឺជាសិស្សពូកែរឺក៏ជាសិស្សមធ្យមរឺក៏ជាសិស្សខ្សោយរឺក៏យ៉ាងមិចដែលទៅអ្នកមីង???

ខៈ

ចាសសំរាប់ជំនាន់នឹងគឺខ្ញុំគឺជាសិស្សមធ្យមហើយក៏មិនសូវជាសិស្សពូកែហើយក៏មិនសូវជាសិស្សខ្សោយអីដែលចឹងហាសចាសហេហេហេហេហេនិយាយទៅ គឺជាសិស្សមធ្យមចាស៕

កៈ

បាទហើយចឹងតើសំរាប់មុខវិជ្ជាអ្វីដែលទៅសំរាប់អ្នកមីងដែលអ្នកមីងបានរៀនពូកែជាងគេដែលទៅអ្នកមីង???

ខៈ

ចាសនិយាយទៅគឺខាងសរសេរដែលខ្ញុំពូកែចឹងហាសហើយសំរាប់ខាងគណិតវិជ្ជានឹងគឺខ្ញុំខ្សោយជាងគេចាសហើយត្រឹមតែក្រៅពីនឹងសំរាប់អោយខ្ញុំនឹងបានមើលអក្សរហើយនឹងបានសរសេរអក្សរនឹងគឺខ្ញុំនឹងមិនជាសូវចាញ់គេនោះទេចាសតែគ្រាន់តែខាងគណិតវិជ្ជានឹងគឺខ្ញុំនឹងចាញ់គេតិចហាសចាសហេហេហេហេ៕

កៈ

បាទហើយហេតុអ្វីដែលបានជាអ្នកមីងរៀនខាងគណិតវិជ្ជានឹងមិនជាសូវពូកែចឹងអ្នកមីង???

ខ៖
ចាសនិយាយទៅគឺខ្ញុំនិយាយប្រាប់ក្មួយឯងទៅហាសសំរាប់នៅក្នុងជំនាន់លុនណលនឹង
ហាសនៅពេលដែលខ្ញុំកំពុងតែរៀនហើយនឹងគ្រូគាត់កំពុងតែពន្យល់នឹងគឺគ្រាប់នឹងបានធ្លា
ប់មកហើយលឺស្វូតែក្តូងចឹងហាសចាសហើយនៅពេលដែលគ្រាប់បានធ្លាប់មកចឹងគឺខ្ញុំនឹង
បានរត់ចូលទៅក្នុងរណ្តៅចឹងហាសចាសហើយមានពេលខ្លះនឹងយើងកំពុងតែរៀនរៀនចឹង
ទៅគ្រាប់គេបានបាញ់មកហើយយើងនឹងបានរត់ទៀតចឹងទៅហើយចឹងហើយបានយើងនឹ
ងរៀនមិនបានគ្រាប់គ្រាន់ចឹងហាសចាសដល់ពេលហើយចឹងទៅវាមើលទៅវាច្របូកច្រប
ល់ចឹងហើយបានយើងនឹងរៀនមិនសូវបានគ្រប់គ្រាន់ចឹងហាសចាសពីព្រោះអីនឹងនៅពេល
ដែលយើងនឹងកំពុងតែរៀននឹងគឺយើងនឹងបានគិតតែរឿងគ្រាប់ភ្លោងរហូតនឹងហាសក្មួយ
ហើយសំរាប់ខ្ញុំនឹងគឺខ្ញុំខំប្រឹងរៀនហើយនឹងបានតស៊ូរដែលហាសទ្រំរាំមតែបានចេះបិននឹង
ហាសចាសគឺខ្ញុំនឹងខំប្រឹងតស៊ូមែនទែនតែម្តងហាសគឺមិនមែនតស៊ូលេងលេងនោះទេចាស
ហើយនៅពេលនឹងគឺដឹងតែមានគ្រប់បាញ់ហើយនឹងគ្រាប់ភ្លោងនឹងតែម្តងហាសចាសនឹង
ហើយគឺវាតាមដំណាល់សំរាប់ខ្សែជីវិតរបស់អ្នកមីងតែម្តងហាសចាសដែលខ្ញុំនឹងកំពុងតែ
រៀនហាសហើយប្រសិនជានៅក្នុងជំនាន់នឹងគឺប្រសិនជាមិនមានគ្រាប់ភ្លោងនឹងគឺជីវិតរប
ស់ខ្ញុំនឹងគឺថាខ្ញុំនឹងអាចរៀនបានច្រើនដែលចឹងហាសចាសហើយក៏មិនសូវជាចាញ់ក្មេងជំ
នាន់ក្រោយប៉ុន្មាននោះដែលចឹងហាសចាសតែសំរាប់ខ្ញុំនឹងគឺខ្ញុំតស៊ូរនឹងគ្រាប់ភ្លោងនឹងតែម្ត
ងហាសចាសហើយគ្រាន់តែគ្រាប់នឹងបានមកចឹងគឺសិស្សសាលានឹងគឺបានក្រោបទាំងអស់
ចឹងហាសហើយនៅពេលដែលគ្រាប់បានមកចឹងគឺយើងនឹងនៅតែតស៊ូរចឹងហាសហើយ
នៅពេលដែលគ្រាប់លេងបានមកចឹងគឺយើងទាំងអស់គ្នានឹងបានក្រោកមករៀនទៀតចឹង
ហាសចាសហើយគិតទៅតាំងពីខ្ញុំនឹងចេះចូលរៀនតាំងពីជំនាន់លុនណលហើយមកដល់ជំ
នាន់ពោលពតទៀតហើយមកជំនាន់ពោលពតនឹងគឺនៅពេលដែលរៀបបណ្តាលគឺរត់ប
ណ្តាលចឹងហាសចាសហើយនៅពេលដែលរៀននៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំរៀននៅក្នុ
ងព្រៃទេហាសចាសហើយយើងគ្មានសាលារៀននោះទេចាសហើយយើងមានតូបហើយមា
នក្រោមដើមឈើចឹងទៅហាសហើយយើងនឹងបានទៅរៀនរៀនហើយនៅពេលដែលយើង
បានទៅរៀនចឹងស្រាប់តែពេលនឹងបានលឺងើងហើយបានហើយចឹងបានសាលារៀនដែល
នៅជំនាន់ពោលពតនឹងហាសគឺយើងបានជីកអណ្តៅដូចជាកន្លែងគេបានធ្វើសង្គ្រាមចឹង
ហាសចាសហើយនៅពេលដែលជីកនឹងគឺមានជនលោះនឹង២រឺក៏៣ចឹងទៅហើយគឺគេបាន
ហោះស្លាបមកហើយហើយសំរាប់គ្រូនឹងគឺគាត់បានគៀលកូនសិស្សនឹងបានចូលទៅក្នុងនឹ
ងទាំងអស់ហើយចឹងហាសហើយនៅពេលដែលយើងមើលទៅវាស្ងាត់ហើយហើយទំលាក់
គ្រាប់នឹងនៅកន្លែងចឹងតតែគេនឹងបានទៅបាត់ចឹងបានយើងនឹងបានឡើងទៅរៀនទៀតចឹ
ងហាសចាសហើយសំរាប់ម្នាក់ម្នាក់ប្រសិនជាពួកគាត់នឹងមិនបានតស៊ូរហាសនៅក្នុងមួយ
ជំនាន់នឹងហាសគឺគ្មាននាក់ណាម្នាក់ចេះអក្សរមួយតួរនោះទេចាសតែយើងនឹងចេះតែតស៊ូរ
ចឹងហាសពីព្រោះអីនឹងយើងបានគិតថាសំរាប់នាក់ផ្សេងនឹងគឺគេធ្វើបានហើយសំរាប់យើង
នឹងក៏អាចធ្វើបានដែលចឹងហាសចាសហើយដល់ពេលនឹងក៏យើងនឹងអាចរៀនបានដែលចឹ

ងហាសចាសហើយនិយាយទៅគឺយកគ្រាប់មុខវិជ្ជាអីខ្លះចឹងទៅហើយនៅពេលដែលចប់ពោលពតនឹងគឺវាមានរយះពេលពោលពតនឹងហាសចាសហើយសំរាប់ម្ដាយនៅដោយហើយសំរាប់ឪពុកនឹងគឺនៅដោយឪពុកចឹងហើយសំរាប់កូននៅដោយកូនចឹងទៅហើយប្រសិនជាយើងនឹងចង់ជួបនឹងម្ដាយហើយនឹងឪពុកនឹងក៏គ្មានពេលនឹងជួបពួកគាត់ដែលចឹងហាសចាសហើយសំរាប់បបរមួយឆ្នាំងនឹងមានចំនួន ១០

នាក់ចឹងទៅហើយសំរាប់អង្ករនឹងយ៉ាងច្រើននឹងគឺមានតែមួយចានចង្កឹងនឹងហាសគឺគ្មានសាច់បបរនោះទេចាសហើយយើងនឹងបានចែកគ្នាសំរាប់ហូបចឹងទៅហើយនៅពេលដែលហូបហើយចឹងទៅហើយយើងនឹងបានទៅធ្វើការងារទៀតចឹងទៅហើយសំរាប់មនុស្សម្នាក់នឹងគឺបានបបរនឹងបានមួយស្លាបព្រាបាយហើយពួកគេនឹងបានយកយើងនឹងទៅលត់ដុំហើយដល់ពេលមែនទែនទៅហាសចាសដល់ពេលមែនទែនទៅគឺពួកវានឹងមិនបានមើលម៉ោងនោះទេចាសហើយសំរាប់ព្រឹកព្រលប់ឡើងនឹងគឺពួកវានឹងនៅចាំមើលសត្វនឹងបានហើលចេញចាសគឺហើលកាត់តាមនឹងចឹងហាសចាសនឹងក៏យើងនឹងគេបានអោយចុះទៅធ្វើការងារចឹងដែលចាសហើយដល់ពេលល្ងាចឡើងទៅដល់ពេលដែលសត្វនឹងបានឡើងត្រនុំហើយសំរាប់សត្វហើលទាំងហ្វូលទាំងហ្វូលហើលចូលត្រនុំនឹងបានពួកវានឹងបានអោយនឹងបានឡើងហាសចាសហើយនៅពេលដែលបានឡើងមកនឹងគឺយើងទាំងអស់គ្នានឹងបានចែករបកគ្នាចឹងទៅហើយនិយាយទៅគឺចែកអោយយើងនឹងហូបមិនបានឆ្អែតចឹងហាសចាសតែសំរាប់យើងនឹងចេះតែហូបចឹងទៅហាសចាសនិយាយទៅគឺវេទនាណាស់នៅក្នុងជំនាន់ពោលពតនឹងហាសទ្រំរាមបានបិននឹងហាសចាសថាមានអ្វីហូបហើយនឹងគ្មានអ្វីនឹងហូបសំរាប់សព្វថ្ងៃនឹងហើយនិយាយទៅកាល់នៅក្នុងវ័យកុមារគឺគេបានយកយើងនឹងមកលុកដំដួចថាជញ្ជូលស្រូវហាសដូចថានៅពេលដែលទឹកនឹងបានឡើងនឹងគឺថាយើងនឹងបានជញ្ជូលរហូតដល់យើងនឹងទន់ចង្កុងហើយទោះបីជាយើងនឹងជញ្ជូលរហូតដួលនឹងក៏យើងនឹងនៅតែក្រោកឡើងដើម្បីនឹងជញ្ជូលទៀតចឹងហាសចាសនឹងហើយគឺគេហៅស្រូវនឹងលិចទឹកហាសហើយពេលនឹងគឺបានកំលាំងប្រុសប្រុសជួយច្រូតចឹងហាសចាសហើយយើងនឹងជាស្រីនឹងជួយធ្វើការងារផងអីផងចឹងហាសហើយដល់ពេលដែលស្រូវនឹងគឺមានចំនួនច្រើនណាស់ណាស់តែនៅពេលដែលយើងធ្វើបានហើយចឹងគឺគេមិនបានអោយនឹងបានហូបនោះទេចាសហើយយើងនឹងមិនដឹងគេយកស្រូវទាំងអស់នឹងយកទៅណានោះទេចាសហើយនិយាយទៅស្រូវនឹងគឺមើលដាច់កន្ទុយភ្នែកចឹងហើយខ្ញុំបានជញ្ជូលជញ្ជូលហើយនឹងស្រូវនឹងហាសចាសតែសំរាប់មកដល់ពេលដែលបានហូបនឹងគឺវាមានភាពវេទនាណាស់ចាសហើយគឺយើងនឹងមិនបានដឹងថាគេបានយកស្រូវហើយនឹងអង្ករនឹងយកទៅទុក្ខនៅកន្លែងណានោះទេចាសគឺវាចឹងហាសគឺវាមានភាពវេទនាចឹងហាសក្ទួយហើយសំរាប់បបរវិញនឹងគឺមានតែទឹកនោះទេហើយយើងមិនដែលបានស្គាល់ថាមានសាច់ជ្រូកហើយនឹងសាច់ត្រីនឹងបានមកហូបនោះទេចាសហើយអំបិលហើយនឹងប៊ីចេងនឹងគឺយើងនឹងមិនដែលបានស្គាល់នោះទេចាសហើយនៅពេលដែលគេបានសួរអោយនឹងបានហូបនឹងក៏គេមិនបានដាក់អ្វីអោយយើងនឹងបានហូបបានឆ្ងាញ់ដែលចឹងហាសតែយើងនឹងចេះតែហូបហូបចឹងទៅហា

សនិយាយទៅអោយតែបានតឹងតឹងពោះហើយនឹងបានធ្វើការងារចឹងទៅហើយនៅពេលដែលយើងនឹងចង់បានជួបមុខឪពុកហើយនឹងម្ដាយរបស់យើងនឹងគឺវានឹងមិនបានអោយយើងនឹងបានជួបនោះទេគឺពួកវានឹងបានបំបែកយើងអស់ហើយចឹងហាសចាសហើយម្នាក់នេះត្រូវជាបងហើយនឹងម្នាក់នេះជាមៀរចឹងចាសគ្រាន់តែបានដឹងហើយចឹងគឺពួកវានឹងបានមកបំបែកយើងចឹងពួកវានឹងមិនបានអោយយើងនឹងបានជួបនោះទេចាសហើយសំរាប់ពួកវានឹងគឺពួកវានឹងបានអោយយើងនឹងនៅតែរៀនចឹងតែអោយយើងនឹងរៀននៅក្នុងរំបោបរបស់ពួកវានឹងនិយាយទៅអោយយើងនឹងបានរៀននឹងគឺដើម្បីយកកំលាំងរបស់យើងនឹងយកទៅប្រើដែលចឹងហាសចាសហើយរៀនអីនឹងគឺរៀនដូចជារៀនក្រៅម៉ោងចឹងហាសចាសហើយនិយាយទៅធ្វើយ៉ាងមិនពួកវានឹងមិនបានអោយយើងនឹងបានសំរាក់នោះទេចាសហើយរៀនផងធ្វើការងារផងចឹងទៅចាសហើយប្រសិនជានិយាយទៅពីរឿងជំនាន់ពោលពតនឹងគឺវាវេទនានឹងមានហាស់និស្ស័យហើយចឹងហាសចាស៕

ក៖
បាទហើយចឹងខ្ញុំចង់សួរអ្នកមីងបកក្រោយមកចេះចឹងនៅពេលដែលអ្នកមីងចឹងគឺរៀនដោយគ្មានសាលារៀនបានត្រឹមត្រូវនោះទេមែនដែលអ្នកមីងគ្រាន់តែមានផ្ទះតូចសំរាប់អ្នកមីងរៀនចឹងមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគេមានផ្ទះតូចមួយសំរាប់អោយយើងនឹងបានរៀនចឹងហាសចាសនិយាយទៅវាដូចជាផ្ទះវែងចឹងហាសហើយមើលទៅដែលមានតុរបស់គឺនឹងមានមួយជួរមួយជួរនោះហើយសំរាប់តុមួយជួរនឹងគឺគេបានដាក់អោយយើងនឹងទៅហើយអោយយើងនឹងរៀននៅក្នុងព្រៃនឹងទៅចាសនិយាយទៅគឺយើងរៀនតែនៅក្នុងព្រៃនឹងហាសចាសហើយគេមិនបានអោយយើងបានរៀននៅក្នុងភូមិនោះទេចាសហើយយើងនឹងនឹកឃើញថានៅពេលដែលយើងនឹងបានរៀននៅភូមិចឹងមានប្រជាជនច្រើនហើយខ្លាចគេនឹងទំលាក់គ្រាប់បែកចឹងហាសចាសនឹងហើយបានគេមិនចង់អោយយើងនឹងបានរៀននៅក្នុងភូមិចឹងហាសហើយចឹងហើយបានគេអោយយើងនឹងបានរៀននៅក្នុងព្រៃទៅហើយនិយាយទៅគឺវេទនាណាស់ហើយនិយាយទៅគឺពួកវានឹងអោយយើងនឹងបានរៀននៅក្នុងព្រៃនឹងតែម្ដងគឺវាមិនបានអោយយើងនឹងបានរៀននៅក្នុងភូមិនោះទេចាសសំរាប់តែវត្តអារាមនឹងក៏មានលោកសង្ឃដែលហាសហើយនិយាយទៅគឺពួកវានឹងមិនជាចង់អោយយើងនឹងបានរៀនសូត្រនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានទំលាក់គ្រាប់បែកចឹងហើយពួកគេបានអោយអ្នកមីងបានរៀននៅក្នុងព្រៃចឹងសំរាប់អ្នកមីងរៀនមិនជាសូវបានគ្រប់គ្រាន់នោះទេមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅរៀនអីបានគ្រប់គ្រាន់បើលយើងនឹងចេះតែរវល់នឹងរត់ចឹងហើយនៅពេលដែលគ្រូគាត់កំពុងតែពន្យល់ចឹងហើយនឹងចូលចិត្តដល់សំណួរហើយចឹងហើយយើងនឹងមិនទាន់បាននឹងចំលងផងនឹងគឺយើងនឹងបានរត់ទៀតហើយចឹងហើយរត់នឹងនៅពេលដែលស្ងាត់ស្ងាត់នឹងមកចឹងទៅស្រួលមិនស្រួលនឹងមកចឹងទៅគឺយើងនឹងបានភ្លេចនឹងគ្រូនឹងបានពន្យល់នឹងទៀតហើយចឹងហាសចាស៕

ក៖
បាទហើយចឹងខ្ញុំចង់សួរអ្នកមីងមួយទៀតថាតើនៅពេលដែលគេមិនបានអោយអ្នកមីងរៀនបានគ្រប់គ្រាប់ចឹងសំរាប់អ្នកមីងមានអារម្មណ៍យ៉ាងមិចដែលទៅអ្នកមីង???

ខ៖
ចាសនិយាយទៅនៅពេលដែលខ្ញុំរៀនមិនបានគ្រប់គ្រាប់ចឹងគឺខ្ញុំមានអារម្មណ៍ថាខ្ញុំនឹងតូចចិត្តនឹងខ្លួនឯងចឹងហាសចាសបានជាខ្ញុំនឹងបានតូចចិត្តនឹងខ្លួននឹងបានសព្វថ្ងៃនឹងខ្ញុំបានជំរុនអោយកូនចៅរបស់ខ្ញុំនឹងខំប្រឹងនឹងបានរៀនសូត្រអោយបានច្រើនចឹងហាសកុំអោយដូចខ្ញុំនៅពេលដែលខ្ញុំនឹងបានកើតមកគឺវាបានកើតមកចំកន្លែងវេទនាដែលជាកន្លែងពិបាក់ណាស់ក្មួយចាស៕

ក៖
ហើយចឹងខ្ញុំចង់សួរទៅកាន់អ្នកមីងតទៀតថានៅពេលដែលអ្នកមីងរៀនមិនបានគ្រប់គ្រាន់ចឹងថាតើសំរាប់អ្នកមីងមានអារម្មណ៍យ៉ាងមិចដែលទៅអ្នកមីង???

ខ៖
ចាសខ្ញុំគ្រាន់តែមានអារម្មណ៍ថាតូចចិត្តខ្លួនឯងចឹងហាសចាសហើយសំរាប់ខ្ញុំនឹងខ្ញុំស្តាយនឹងតំរះមួយរបស់យើងនឹងទាំងមូលចឹងហាសចាសពីព្រោះអីនឹងយើងមិនបានរៀនចឹងហាសនៅក្នុងឆាក់ជីវិតរបស់យើងចឹងហាសហើយសំរាប់នៅក្នុងមនុស្សម្នាក់ម្នាក់នឹងដែលយើងមិនបានរៀនហើយយើងនឹងចេះតែមានតំរះនឹងបានទៅមុខចឹងហាសហើយសំរាប់យើងនឹងគឺយើងនឹងខំប្រឹងតស៊ូរដែលតែធ្វើយ៉ាងមិចគឺយើងនឹងទៅវាមិនរួចបានត្រឹមតែប៉ុននឹងនោះទេចឹងហើយបានយើងនឹងមានភាពពិបាក់ចឹងតែយើងនឹងបានគ្រាន់តែមួយតូចចិត្តនឹងខ្លួនឯងចឹងហាសតែយើងនឹងមិនដឹងធ្វើយ៉ាងមិចនោះទេតែសំរាប់ខ្ញុំនឹងគឺចង់ចេះហើយនឹងតំរះវិជ្ជានឹងដែលក៏ប៉ុនតែសំរាប់ស្រុករបស់យើងនឹងគឺមានបញ្ហាស្រុកទេសចឹងហាសចាសគឺយើងនឹងមិនបានរៀននោះទេចេះតែរត់ទៅនេះហើយនឹងរត់ទៅនោះចឹងហាសចាសហោហោហោហោហើយសំរាប់មួយជំនាន់របស់ខ្ញុំនឹងគ្មាននាក់ណាដែលគាត់សួរចេះនោះទេចាសបានថាយើងនឹងកំពុងរត់ហើយនឹងរត់លូនហាសចាសដល់ពេលដែលយើងបានចប់ឆ្នាំ១៩៧៩

នឹងមកគេក៏បានមករៀនចឹងហាសហើយសំរាប់ខ្ញុំនឹងក៏បានពេញវ័យហើយចឹងហាសហើយណាមួយនឹងទៀតគឺខ្ញុំនឹងបានរស់នៅជាមួយនឹងម្ដាយរបស់ខ្ញុំចឹងហាសហើយខ្ញុំនឹងក៏បានចូលទៅធ្វើការងារជាមួយនឹងគេចឹងទៅហើយសំរាប់ខ្ញុំក៏មិនបានរៀនបន្តទៀតនោះទេគឺគ្មាននោះទេចាសហើយនៅពេលដែលខ្ញុំនឹងបានគិតនឹងគឺខ្ញុំមានអារម្មណ៍វាមានភាពវេទនាណាស់ទៅហើយចឹងហាសហើយនៅពេលដែលចប់ហើហាយចឹងទៅហើយយើងនឹងបានពេញរូបហើហាយនឹងពេញរាងចឹងទៅហើយយើងនឹងបានពេញកំលាំងនឹងទី១ចឹងទៅក៏ខ្ញុំនឹងបានចូលទៅក្រុមរបស់គេចឹងទៅហើយនៅពេលដែលយើងនឹងបានទៅក្រុមរបស់គេចឹងទៅគឺយើងនឹងមើលខ្លួនឯងនឹងមិនបានយល់នោះទេពីព្រោះអីនឹងគឺយើងខ្មៅចឹងហាសចាសនិយាយទៅគឺយើងខ្មៅដូចជាធ្យូងចឹងហើយសំរាប់បងប្អូនរបស់យើងនឹងប្រសិនជាមើលគ្នានឹងគឺមើលរាប់ខែបានយើងនឹងបានស្គាល់ចឹងហាសចាសហើយនៅពេលដែលកូនបានឃើញម្ដាយហើយនឹងម្ដាយឃើញកូនចឹងមានធ្វើអ្វីបាននោះទេមានតែយំចឹងទៅហើយបានអោបគ្នាចឹងទៅហើយនៅពេលដែលយើងនឹងបានមកដល់មួយយប់ចឹងទៅគឺយើងនឹងបានទៅវិញទៅហើយសំរាប់យើងនឹងគឺជាប់មុខគ្នានឹងមិនបានស្រួលបល់នោះគឺយើងនឹងបានមកដោយតក់ក្រហាលចឹងហាសចាសហើយសំរាប់ថ្ងៃណាដែលយើងនឹងបាននឹកគាត់ពេកនឹងគឺយើងបានលួចមកតែម្ដងចឹងហាសចាសនិយាយទៅគឺយើងបានប្ដូរជីវិតហាសដែលយើងពីព្រោះអីនឹងគឺយើងនឹងនឹកឪពុកហើយនឹងម្ដាយរបស់យើងចឹងហាសចាសនិយាយទៅគឺយើងនឹងប្ដូរដោយសារតែយើងនឹងនឹកចឹងហាសចាសហើយនៅពេលដែលយើងនឹងបានជួបគាតើហើយចឹងគឺគ្មានធ្វើអ្វីបានក្រៅពីយើងនឹងអោបគ្នាហើយនឹងបានយំនោះទេចាសហើយសំរាប់មួយជំនាន់នឹងគឺពិបាកខ្លាំងណាស់ហើយប្រសិនជាយើងនឹងបានត្រូវជាមួយនឹងប្រធានភូមិរបស់យើងនឹងហើយនឹងមេកងគឺគេចេះតែជួយយើងចឹងទៅហាសចាស៕

ក៖
បាទហើយចឹងសំរាប់អ្នកមីងកាល់ដែលអ្នកមីងនៅពីក្មេងនឹងដែលនៅក្នុងជំនាន់ពោលពតនឹងថាតើអ្នកមីងបានរស់នៅភូមិអ្វីហើយនឹងស្រុកអ្វីដែលទៅអ្នកមីង???

ខ៖
ចាសនៅក្នុងជំនាន់ដែលខ្ញុំនឹងនៅក្មេងនឹងគឺខ្ញុំបានរស់នៅខាងកោះដាច់ចឹងហាសចាសហើយសំរាប់កន្លែងនឹងក៏ជាស្រុកកំណើតរបស់ខ្ញុំនឹងហើយសំរាប់ដីធ្លីនឹងក៏នៅកន្លែងនឹងដែលចឹងហាសចាសចុះយើងនឹងបានគិតថាវានៅបិននឹងបិននឹងហាសចាសនិយាយទៅគឺនៅខាងកោះដាច់ដែលផ្លូវឡើងមកដល់ទូតដររបស់យើងនឹងហាសចាសនិយាយទៅខ្ញុំនៅកន្លែងនឹងហាសចាសនិយាយទៅគឺនៅជិតដែលចឹងហាសហើយសំរាប់យើងនឹងវានៅជិតនឹងដែលដល់ពេលដែលយើងនឹងបានរស់នៅគឺយើងនឹងបានធ្វើការងារចំការចឹងហាសចាសគឺយើងធ្វើការចំការអីនៅកន្លែងនឹងហាសចាសដល់ពេលដែលយើងនឹងបានធ្វើចំការហើយចឹងហើយសំរាប់លុនណាលនឹងគឺគេបានជំលាស់យើងនឹងទៅលិចទៅកើតចឹងទៅហើយពេ

លនឹងក៏យើងនឹងបានមករស់នៅស្រុកកំណើតរបស់យើងវិញមកចាសនិយាយទៅគឺស្រុក កំណើតរបស់យើងនឹងនៅនឹងតែម្តងហាសចាសហើយគេបានមកចង់សំលាប់យើងហាស ក្មួយហើយសំរាប់ដំបន់នឹងគឺគេបានហៅថាជាតំបង ៤២ ហើយនឹងតំបន់ ២២ ហាសហើយសំរាប់តំបន់
៤២នឹងគឺគេបានសំលាប់មនុស្សច្រើនណាស់រួចហើយមកល់តំបន់
២២នឹងគឺគេបានអោយយើងនឹងបានហូបចឹងហាសហើយប្រសិនជាគេបានដាំបាយដាក់ជាមួយនឹងពោតគឺគេបានដាក់ពោតសុទ្ធចឹងហាសចាសហើយនិយាយទៅគឺមានមួយកន្លែងនឹងមានធូហើយនឹងមានកន្លែងនឹងខ្លះវាតឹងចឹងហាសចាសហើយពួកគេបានហៅពួកនឹងថាពួកចាកីក្រហមចឹងហាសហើយសំរាប់ពួកនឹងគឺពួកវានឹងគិតតែសំលាប់តែម្តងហាសហើយ ប្រសិនជាយើងនឹងបានយកផ្លែពោតនឹងបានមួយនឹងក៏វានឹងបានកាប់ម្រាមដៃរបស់យើងនឹងមួយដែលចឹងហាសចាសដែលពួកវានឹងនៅខាងកោះដាច់នឹងហាសហើយនៅពេលដែល ខ្ញុំនឹងទ្រាំមិនបាននឹងក៏ខ្ញុំនឹងបានរត់មករស់នៅនៅទីកន្លែងនឹងទាំងយប់ចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានមកនៅនឹងចឹងទៅគឺគេបានជួយលាក់យើងនឹងកុំអោយគេនឹង បានដឹងចឹងទៅហាសចាសហើយសំរាប់គេបានជួយលាក់យើងនឹងគាត់គឺជាប្រធានភូមិចឹង ហាសពីព្រោះអីនឹងពួកគាត់បានអាណិតប្រជាជនចឹងហាសចាសហើយសំរាប់កាល់នឹងគឺ គេមិនបានសួរមាននាក់សំលាប់ដែលចឹងហាសកាល់នឹងនៅទីកន្លែងនឹងហាសចាសហើយ សំរាប់ស្រុកកោះនឹងក៏វាមិនដូចជាស្រុកកោះផ្សេងដែលចឹងហាសចាសដល់ពេលហើយចឹងម្នាក់ម្នាក់ក៏បានរត់មករស់នៅមូលទាំងអស់គ្នានៅកន្លែងនឹងហាសចាសហើយប្រសិន អោយអ្នកផ្សេងនឹងមកនឹងគឺមិនអីនោះទេចាសហើយសំរាប់ការដែលយើងធ្វើយ៉ាងមិចក៏គេ មិនបានដឹងដែលហើយធ្វើយ៉ាងមិចអោយតែបានមកដល់កោះឧកញ្ញាតីនឹងគឺគេបានអោយ យើងនឹងបានជួយលាក់ការគ្នាចឹងហាសចាសគឺគេមិនបានអោយអ្នកដែលនៅខាងនោះនឹង មិនអោយគេបានមករកយើងនឹងបានឃើញនោះទេចាសហើយដល់ពេលចឹងទៅគឺយើងនឹងបានរួចមានជីវិតចឹងទៅកុំអីនឹងគឺខ្ញុំនឹងបានស្លាប់ហើយក្មួយអើយហើយកុំអីនឹងគ្រួសាររបស់ខ្ញុំនឹងត្រូវបានស្លាប់ទាំងអស់នឹងហាសចាសហើយប្រសិនជាគេបានដឹងថាយើងនឹងចង់រត់ទៅណាចឹងគឺយើងនឹងត្រូវគេនឹងបានសំលាប់ចោលហើយគឺមិនចាំបាច់រត់នោះទេហើយ អោយតែដឹងថាយើងនឹងមានឈ្មោះរបស់គេនឹងសំលាប់យងចោលចឹងហាសចាស។

ក៖
បាទហើយចឹងអរគុណាច្រើនអ្នកមីងខ្ញុំចង់សួរទៅកាន់អ្នកមីងមួយទៀតថាតើនៅពេលដែល អ្នកមីងនៅក្នុងជំនាន់ពោលពតនឹងថាតើអ្នកមីងមានអាយុប៉ុន្មានដែលទៅអ្នកមីងសំរាប់អ្នក មីងហាស???

ខ៖ ចាសសំរាប់ខ្ញុំនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំមានអាយុ ១៤ រឺក៏ ១៥ឆ្នាំ
អីនឹងហាសហើយសំរាប់អាយុប៉ុននឹងគឺខ្ញុំកំពុងតែពេញសិក្សាចឹងហាសចាស។

ក៖ បាទហើយចឹងសំរាប់អ្នកមីងនៅពេលដែលអ្នកមីងអាយុ ១៤ឆ្នាំរឺក៏ ១៥ឆ្នាំនឹងចឹងថាតើគេបានអោយអ្នកមីងបានធ្វើការងារអ្វីដែលទៅអ្នកមីងហើយដែលគេបានអោយអ្នកមីងធ្វើការងារដែលធ្ងុងហើយនឹងពិបាក់ចឹងហាស???

ខ៖ ចាសសំរាប់ជំនាន់ពោលពតនឹងគឺគេបានអោយខ្ញុំធ្វើការងារដូចជារ៉ែកដីហើយនឹងជញ្ជូលស្រូវហើយនឹងស្ទូងស្រូវចឹងហាសហើយសំរាប់ជញ្ជូនសំនាប់អោយគេចឹងហាសកាល់នឹងគឺយើងនឹងបាននៅក្មេងដែលហើយពីព្រោះអីនឹងគឺយើងនឹងបានក្មេងជាងគេចឹងហាសហើយសំរាប់គេនឹងគឺមានវ៉យចំណាស់ជាងចឹងចាសហើយដល់ពេលចឹងទៅគឺគេបានអោយយើងនឹងបានរ៉ែកដីហើយនឹងជញ្ជូនសំនាបអោយចឹងទៅចាសហើយសំរាប់ពេលនឹងគឺយើងនឹងកំពុងតែពេញកំលាំងហាសនៅពេលដែលយើងនឹងមានវ៉យ ១៤ឆ្នាំរឺក៏១៥ឆ្នាំនឹងហាសចាសនិយាយទៅគឺគេបានប្រើយើងចឹងហាសគឺគេបានអោយយើងនឹងធ្វើការងាររ៉ែកដីហើយនឹងងរ៉ែកសំនាបអោយចឹងទៅចាសហើយប្រសិនជាគេអោយយើងនឹងទៅរ៉ែកទំនុបចឹងទៅយើងនឹងទៅរ៉ែកដីអោយគេចឹងទៅចាសហើយនិយាយទៅគឺទាំអថ្ងៃហើយនឹងទាំងយប់ចឹងទៅចាសហើយទាំងអស់នឹងគឺជាការងារដែលធ្ងង់របស់យើងនឹងហាសពីព្រោះអីនឹងយើងកំពុងតែមានកំលាំងចឹងហាសចាសហើយយើងមានអាយុ១៤ឆ្នាំរឺក៏១៥ឆ្នាំហើយគេបានអោយយើងនឹងបានរ៉ែកដីហើយនឹងបានរ៉ែកសំនាបអោយគេចឹងទៅហើយគេបានអោយយើងនឹងរ៉ែកសំនាបហើយនឹងរ៉ែកស្រូវហើយនឹងរ៉ែកកណ្ដាបអោយគេចឹងទៅចាសនិយាយទៅគឺគេត្រូវតែប្រើយើងនឹងអោយពេញកំលាំងនឹងហាសចាសហើយសំរាប់ការប្រើនឹងគឺគេប្រើយើងនឹងគឺប្រើប្រើពេកហាសក្មួយចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានប្រើអ្នកមីងលើសកំលាំងដូចជាមនុស្សប្រុសចឹងថាតើគេបានអោយអ្នកមីងនឹងបានហូបបានឆ្អែតដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយទៅគឺដូចខ្ញុំនឹងបាននិយាយចឹងសំរាប់អង្ករនឹងបានមួយឆ្នាំងនឹងមានចំនួន ១០
នាក់ចឹងហើយសំរាប់បាយនឹងគឺបានតែមួយស្លាបព្រាចឹងហាសហើយសំរាប់បបរចឹងយើងទាំងអស់គ្នានឹងបានហូបបានតែទឹកបបរអីហើយចឹងទៅហើយនៅសល់សំលេងបាតឆ្នាំរបស់គេចឹងទៅគឺគេបានរល់ចែកគ្នាចឹងហាសហើយយើងនឹងហូបតែទឹកចឹងទៅហើយនៅសល់កាក់បាយមួយចានចឹងគឺយើងបានយកវាមកហើយយើងបានចែកគ្នាបានម្នាក់មួយស្លាបព្រាចឹងទៅហាសចាសហើយយើងចែកគ្នាចឹងទៅអោយបានស្គាល់រស់ជាតិអង្ករចឹងហាសចាសហើយនិយាយទៅនៅពេលដែលគេបានប្រើយើងហើយទាំងពេញកំលាំងចឹងហើយតែសំរាប់ពួកគេនឹងគឺគេមិនបានអោយយើងនឹងបានហូបបានគ្រប់គ្រាន់នោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងហូបមិនបានគ្រប់គ្រាន់ហើយចឹងហើយអ្នកមីងធ្វើការងារច្រើនហួសកំលាំងចឹងថាតើសំរាប់អ្នកមីងមានជំងឺឈឺហើយនឹងមានកំលាំងនឹងធ្វើការងារដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺឈឺដែលចឹងហាសហើយសំរាប់ដល់ពេលយប់ចឹងទៅយើងនឹងបានដេកឈឺចឹងទៅគឺយើងបានឈឺខ្លួនហើយនឹងឈឺប្រាណអីចឹងទៅហើយសំរាប់យើងនឹងគឺយើងនឹងក្រោកមិនចង់រួចពីកន្ទេលនោះទេតែយើងធ្វើយ៉ាងមិចគឺយើងត្រូវតែធ្វើចឹងទៅទាំងយើងមិនចង់ចឹងហាសចាសហើយប្រសិនជាយើងនឹងបានធ្វើការងារនឹងគឺគេនឹងមិនបានអោយនឹងបានហូបបាយនោះទេរឺក៏បបរចាសហើយនិយាយទៅសូមបីតែរកទឹកបបរនឹងសំរាប់ហូបនឹងមិនចង់បានផងចឹងហាសចឹងហើយបានយើងនឹងចេះតែតស៊ូរនៅក្នុងជីវិតរបស់យើងចឹងហាសហើយទោះបីជាកំលាំងរបស់យើងនឹងទៅមិនរួចយ៉ាងណាក៏យើងនឹងត្រូវតែទៅធ្វើការងារអោយគេចឹងហាសចាសនិយាយទៅគឺត្រូវតែប្រឹងតែម្តងហើយសំរាប់យើងនឹងបានក្រោកពីកន្ទេលនឹងមិនចង់រួចផងនឹងក៏យើងនឹងត្រូវតែប្រឹងចឹងហាសចាស៕

ក៖
បាទហើយចឹងប្រសិនជាយើងនឹងបានឈឺចឹងហើយយើងមិនអាចសុំច្បាប់គេដើម្បីនឹងបានសំរាក់បានទេមែនដែលទេអ្នកមីង???

ខ៖
ចាសនៅពេលដែលយើងនឹងបានប្រាប់គេចឹងគឺគេបានអោយយើងនឹងបានទៅពេទ្យចឹងហាសហើយគេបានអោយថ្នាំមកអោយយើងហូបចឹងហាសហើយសំរាប់ថ្នាំរបស់គេនឹងមិនដឹងគេថ្នាំស្អីស្អីនោះទេចាសនិយាយទៅគេបានអោយថ្នាំជាថ្នាំអាចញ់ទន្សាយនឹងហាសចាសហើយសំរាប់ថ្នាំនឹងគឺថ្នាំមានពណ៌ខ្មៅចឹងហាសហើយយើងនឹងចេះតែលេបទៅហាសចាសហើយសំរាប់ជាមិនជានឹងគឺយើងនឹងចេះតែទៅចឹងទៀតចឹងទៅហើយសំរាប់ស្លឹកឈើហើយនឹងស្លឹកព្រៃនឹងគឺយើងនឹងចេះតែបុកផឹកចឹងទៅចាសហើយសំរាប់ស្លឹកដែលនៅក្បែរក្បែរផ្ទះនឹងគឺយើងនឹងចេះតែយកមកបុកផឹកចឹងទៅនិយាយទៅសំរាប់ស្លឹកឈើនឹងវាគ្រាន់បើលជាងថ្នាំរបស់វាចឹងហាសហើយសំរាប់ត្រួយគោលហើយនឹងត្រួយអ្វីផ្សេងនឹងគឺយើងចេះតែបុកសំរាប់ហូបចឹងទៅហាសហើយសំរាប់ថ្នាំខ្មែររបស់យើងនឹងចេះតែបុកហូបចឹងទៅហាសចាសហើយមើលទៅសំរាប់ថ្នាំរបស់វានឹងមើលទៅដូចជាអាចន៍ទន្សាយដូចម្តាយរបស់ខ្ញុំនឹងបាននិយាយចឹងហាសហើយនិយាយទៅគឺខ្មៅហើយតូចតូចបិននឹងឯងចាស៕

ក៖

បាទហើយចឹងនៅពេលដែលអ្នកមីងអត់បានហូបថ្នាំរបស់អង្គការរបស់ពួកពោលពតនឹងហើយប្រសិនជាគេបានដឹងនឹងគេនឹងសំលាប់អ្នកមីងចោលមែនដែលទេអ្នកមីង???

ខ៖

ចាសនិយាយទៅប្រសិនជាគេបានឃើញយើងនឹងបានបោះចោលថ្នាំរបស់គេនឹងគឺគេនឹងយកយើងនឹងទៅកសាងយើងនឹងហើយគឺគេបានដាក់វិន័យអោយនឹងបានឈរចឹងហាសហើយអោយយើងនឹងបានឈរហាលអោយមូសនឹងបានកាំមួយយប់ចឹងទៅហើយស្រួលមិនស្រួលនឹងគឺគេបានយកនឹងទៅវៃចោលទៀតចឹងហាសចាសហើយប្រសិនជាយើងនឹងមិនចង់ហូបទេគឺយើងនឹងយកវាមកហើយយើងចង់យកវាលាក់នៅណារីក៏បោះចោលណាចឹងគឺកុំអោយបានឃើញចឹងហាសចាសពីព្រោះអីនឹងនៅពេលដែលយើងនឹងទៅសុំគេគឺគេបានអោយមកយើងចឹងហាសចាសហើយយើងបានដាក់វានឹងដាក់ចូលទៅក្នុងហោប៉ាវចឹងទៅណាហើយប្រសិនជាយើងហូបមិនបាននោះទេវាជារឿងរបស់យើងតែធ្វើយ៉ាងមិចកុំតែអោយគេនឹងបានឃើញចឹងទៅណាក្មួយហើយប្រសិនជាយើងនឹងហ៊ានតែបោះចោលនៅនឹងមុខរបស់សាក់មើលស្រួលមិនស្រួលនឹងគឺវាយកយើងនឹងទៅសំលាប់ចោលទៅរឺក៏វាយកយើងនឹងទៅកសាងហើយនឹងឈរហាលអោយមូសនឹងបានកាំយើងនឹងមួយយប់ចឹងទៅហើយពួកវានឹងបានកសាងយើងនឹងលោនចាស៕

ក៖

បាទហើយចឹងប្រសិនជាយើងនឹងមិនបានហូបថ្នាំរបស់ពួកពោលពតដែលបានអោយយើងទេពួកគាត់នឹងយកយើងនឹងទៅកសាងរឺក៏យកយើងនឹងទៅសំលាប់ចោលមែនដែលទេអ្នកមីងហើយប្រសិនជាយើងមិនចង់ហូបទេគឺយើងយកថ្នាំនឹងមកលាក់ចឹងទៅមែនដែលទេអ្នកមីង???

ខ៖

ចាសប្រសិនជាយើងមិនចង់ហូបទេយើងយកវានឹងទៅបោះចោលនៅក្នុងអណ្តូលហើយនឹងស្រះអីនឹងចឹងទៅចាសហើយប្រសិនជាយើងចង់បោះចោលនៅណាយើងកប់វានៅនឹងចឹងទៅនិយាយទៅកុំអោយគេបានឃើញចឹងទៅហាសចាសហើយយើងសុខចិត្តទៅបេះស្លឹកត្រួយគោចឹងទៅចាសហើយនិយាយមែនទែនទៅសូម្បីតែត្រួយសាម៉ៅនឹងក៏យើងនឹងមិនទុក្ខដែលចឹងហាសចាសគឺយើងបានយកបុកហូបហាសរឺក៏ត្រួយទំពាំងបាយសរនឹងក៏យកមកដែលហើយសំរាប់ទំពាំងសរនឹងគឺវាមានញ្ញីហើយនឹងឈ្មោលទៀតហាសចាសហើយនិយាយទៅគឺខ្ញុំស្គាល់រស់ជាតិអស់ហើយសំរាប់នៅក្នុងជំនាន់ពោលពតនឹងហាសចាសហើយនិយាយទៅអោយតែបានហូបទៅត្រជាក់ខ្លួននឹងគឺយើងហូបហើយចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានហូបត្រួយស្ទៅហើយនឹងត្រួយសាម៉ៅដែលអ្នកមីងបាននិយាយនឹងថាតើនៅពេលដែលអ្នកមីងបានបុកហូបចឹងហើយអ្នកមីងមិនបានហូបថ្នាំរបស់អង្គការនឹងថាតើអង្គការនឹងបានឃើញអ្នកមីងហូបទាំងអស់នឹងដែលរឺទេអ្នកមីង???

ខ៖
ចាសគឺគេបានឃើញហើយនិយាយទៅដូចថាយើងនឹងធ្វើអ្វីហូបលួចលាក់ចឹងហាសក្មួយហើយគ្មានអ្វីនោះទេគឺក្រមាររបស់យើងនឹងគឺយើងបានបោចហើយនឹងដាក់ជាមួយនឹងក្រមារហើយនឹងបានជុំចាសជុំអោយបែកហើយលាយជាមួយនឹងទឹកពាងនឹងហើយលាយហើយនឹងច្រុះហើយយើងហូបទៅចាសនឹងគឺកំសត់កាល់ដែលនៅក្នុងជំនាន់នឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានហូបចឹងថាតើអ្នកមីងបានមានភាពធូខ្លះដែលរឺទេអ្នកមីង???

ខ៖
ចាសនិយយាទៅប្រសិនជាហូបទៅមកដល់លូវនឹងវាគ្រាន់តែជាថ្នាំត្រជាក់នោះទេចាសហើយសំរាប់មួយនឹងគឺជាថ្នាំបុរាណចឹងហាសចាសហើយសំរាប់ចាស់ចាស់គាត់បានដឹងពីសង្គមមកចឹងហាសហើយមកដល់លូវនឹងហើយគាត់បានធ្វើអោយកូនកូននឹងបានហូបចឹងទៅហាសចាសហើយលូវនឹងគឺចាំមកដល់កូនចៅរបស់យើងទៀតចឹងហាសចាសហើយនៅពេលដែលពកក្បាល់ចឹងហើយវាបានឈឺខ្លាំងមិនបានទៅពេទ្យស្លឹកត្រួយអំពៅនឹងបុកហើយនឹងបានច្រលក់ដាក់ទៅនឹងកន្សែនឹងហើយនឹងបានច្របាច់ហើយនឹងបានដាល់នៅកលក្បាល់របស់ក្មេងចឹងទៅហាសចាសហើយសំរាប់មកដល់លូវនឹងគឺគេបានចេញរបបដែលគេបានបិទក្បាល់របស់គេចឹងទៅហាសចាសហើយយើងបានបិទហើយនឹងបានបច្ចកំក្តៅចឹងទៅហើយសំរាប់មកដល់ជំនាន់របស់ខ្ញុំនឹងគឺគ្មានអាបិទនឹងបច្ចកំក្តៅណាក្មួយគឺយើងមានតែស្លឹកគោនឹងហើយយើងបានច្របាច់ហើយនឹងដាក់ទៅនឹងកន្សែងនឹងហើយដាក់ស្អំចឹងទៅចាសនឹងសំរាប់ទាំងអស់នឹងគឺយើងបានដឹងពីជំនាន់ពោលពតមកចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានហូបថ្នាំនឹងអ្នកមីងបានជាធូរច្រើនមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺយើងបានធូរដែលចឹងហាសហើយហើយយើងបានត្រជាក់បណ្តាលហើយយើងបានធ្វើការងារនឹងបណ្តាលហើយយើងលួចហូបនឹងបណ្តាល់ចឹងទៅហាសចាសគឺដើម្បីទប់នឹងកំក្តៅនឹងហាសហើយសំរាប់ដល់ពេលយប់នឹងយើងចេះតែគ្របដាក់កន្សែង

ហើយចឹងទៅហាសហើយយើងចេះតែធ្វើការងារតែងឈឺតែងជាចឹងទៅហាសចាសហើយពួកគេមិនបានដឹងថាយើងនឹងឈឺរឺក៏ជានោះទេដឹងតែយើងសុំនឹងយើងចេះតែលេបហើយហើយនៅពេលដែលយើងបានមកចឹងយើងលេបមិនបានលេបនឹងគឺជារឿងរបស់យើងចឹងហាសចាសហើយប្រសិនជាយើងនឹងបានឈឺខ្លាំងចឹងគឺគេបានអោយយើងនឹងបានដេកសំរាក់នឹងនៅពេទ្យនឹងបាន២ថ្ងៃរឺក៏៣ថ្ងៃចឹងទៅហើយសំរាប់ថ្នាំរបស់វានឹងមិនដឹងជាស្អីនោះទេហើយប្រសិនជាយើងនឹងមិនបានលេបទេគឺវានឹងសំលាប់យើងចោលចឹងហាសចាសហើយប្រសិនជាយើងនឹងបានឈឺខ្លាំងនឹងគឺគេបានអោយយើងនឹងទៅដេកសំរាក់នៅពេទ្យចឹងទៅចាសហើយសំរាប់ថ្នាំនឹងគឺគេបានប្រចាំការរបស់គេនឹងក្នុងមួយថ្ងៃនឹង២រឺក៏៣ដងចឹងហាសហើយគេអោយយើងនឹងលេបហើយយើងនឹងចេះតែលេបតាមគេចឹងទៅហាសហើយសំរាប់ថ្នាំនឹងត្រូវនឹងយើងនឹងយ៉ាងមិចយ៉ាងមិចយើងនឹងមិនបានដឹងនោះទេគ្រាន់តែគេអោយយើងនឹងលេបចឹងទៅហាសចាសហើយសំរាប់យើងនឹងចេះតែខំប្រឹងលេបចឹងទៅហើយប្រសិនជាយើងនឹងបានលេបហើយស្រួលនឹងចេះតែស្រួលចឹងទៅហើយប្រសិនជាមិនសូវស្រួលនឹងនៅតែចឹងទៅហើយប្រសិនជាយើងនឹងបានស្រួលបានបន្តិចចឹងទៅគឺគេបានអោយយើងនឹងទៅធ្វើការងារទៀតហើយចឹងហាសចាសហើយមិនដូចយើងលូវនឹងនោះទេប្រសិនជាយើងឈឺអីបានបន្តិចបន្តួចនឹងគឺយើងអាបមកសំរាក់នៅពេទ្យចឹងហាសចាសហើយប្រសិនជាយើងសំរាក់បានហើយចឹងរហូតដល់យើងមានកំលាំងនឹងបានស្រួលបួលហើយចឹងបានយើងនឹងបានមកផ្ទះមិនដូចនៅក្នុងជំនាន់ពោលពតនោះទេចាសគឺពួកគេមិនបានដឹងថាយើងនឹងឈឺយើងជានោះទេក្មួយអើយនិយាយទៅគេដឹងតែប្រើយើងតែម្តងហើយប្រសិនជាប្រើយើងហើយហើយអោយយើងនឹងបានហូបគ្រប់គ្រាន់ទៅវាមិនអីទេតែនេះអត់នោះទេចាសហើយសំរាប់ទឹកបបរនឹងនិយាយទៅគឺវារាយតែម្តងហាសចាសហើយប្រសិនជាយើងនឹងឈឺច្រើនពេកនឹងគឺគេថាយើងនឹងឈឺគ្រុនទន្សាយហាសហើយសំរាប់គ្រុនទន្សាយនឹងគឺគេបានហៅថាយើងនឹងគឺជាមនុស្សខ្ជិលហាសចាស៕

កៈ បាទហើយចឹងនិយាយទៅគឺយ៉ាប់ណាស់ហេហេហេហេ???

ខៈ
ចាសនិយាយទៅគឺកំសត់ខ្លាំងណាស់ហើយប្រសិនជាលើកប្រវត្តិមកនិយាយទៅគឺបាយចត់តែម្តងហាសចាសហើយនិយាយទៅគឺសុទ្ធតែឆ្អឹងមាសហើយនឹងឆ្អឹកប្រាក់ហើយបានបានមករស់នៅដល់សព្វថ្ងៃនងឹហាសចាស៕

កៈ
បាទហើយចឹងខ្ញុំចង់សួរទៅកាន់អ្នកមីងបកក្រោយតិចថានៅពេលដែលអ្នកមីងនៅក្មេងនឹងគឺគេមិនបានអោយអ្នកមីងនឹងបានរស់នៅជាមួយនឹងឪពុកហើយនឹងម្តាយរបស់អ្នកមីងមែនដែលទេអ្នកមីងអានឹងមកពីមូលហេតុអ្វីដែលទៅអ្នកមីង???

ខ៖
ចាសមួយនឹងគឺគេថាសំរាប់ម្តាយរបស់យើងហើយនឹងឪពុករបស់យើងនឹងគឺគាត់នៅកំលាំងពេញហើយសំរាប់ខ្ញុំនឹងនៅកំលាំងនឹងនៅពេញចឹងទៅគឺគេបានដាក់យើងនឹងនៅវ៉ៃយកណ្តាលចឹងទៅហាសចាសហើយសំរាប់កំលាំងរបស់ក្មេងចឹងគឺគេបានដាក់នៅវ៉ៃយកុមារចឹងទៅគឺគេបានដាក់ផ្សេងចឹងទៅគឺគេមិនបានអោយយើងនឹងបានរស់នៅជិតពួកគាត់នោះទេចាសពីព្រោះអីនឹងគឺគេបានខ្លាចថាយើងនឹងអាងគ្នាចឹងទៅហាសចាសនិយាយទៅអាងម្តាយហើយនឹងកូនចឹងហាសចាសហើយដល់ពេលដែលនិយាយទៅគឺយើងមិនបានដឹងពីគំណិតរបស់យ៉ាងមិចនោះទេនិយាយទៅគឺពួកវានឹងមិនចង់អោយយើងនឹងបានរស់នៅជាមួយនឹងក្រុមគ្រួសាររបស់យើងនឹងតែម្តងចឹងហាសចាសហើយនិយាយទៅគឺគេបានបំបែកមិនបានជួបគ្នានឹងតែម្តងហាសចាសហើយនិយាយទៅគឺគេបាននិយាអំពីកំណាព្យថានៅផ្ទះម្តាយទីទៃហើយនៅព្រៃម្តាយតែមួយចឹងហាសចាសដល់ពេលហើយចឹងទៅកូនរបស់គេនឹងបានមករស់នៅជាមួយនឹងយើងហើយសំរាប់កូនរបស់យើងនឹងទៅរស់នៅជាមួយនឹងគេចឹងទៅហាសចាសហើយសំរាប់ម្តាយរបស់គេមករស់នៅជាមួយនឹងម្តាយរបស់យើងហើយម្តាយរបស់យើងនឹងទៅរស់នៅជាមួយនឹងម្តាយរបស់គេចឹងទៅហាសចាសនិយាយទៅគឺវាច្របូកច្របល់ហាសចាសនិយាយទៅដូចថាសំរាប់ម្តាយរបស់គេនឹងបានទៅធ្វើការងារហើយយើងនៅផ្ទះចឹងហាសគឺចាស់ចាស់នឹងគឺគេបានអោយយើងនឹងនៅមើលក្មេងចឹងហាសចាស៕

ក៖
បាទហើយចឹងបានន័យថាសំរាប់ចាស់ចាស់គឺគេបានអោយរស់នៅជាមួយនឹងចាស់ចាស់ហើយសំរាប់ក្មេងក្មេងនឹងគឺគេបានអោយរស់នៅជាមួយនឹងក្មេងក្មេងមែនដែលរឺទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគេបានអោយយើងនឹងបានរស់នៅបែកគ្នាទាំងអស់ចឹងហាសហើយសំរាប់បងប្អូនរបស់យើងនឹងគេបានអោយទៅរស់នៅម្តុំចឹងទៅនិយាយទៅដូចថាខាងនេះសំរាប់កោះឧកញ្ញាតីចឹងទៅហាសហើយគេបានមករស់នៅមួយសហាករចឹងហើយដល់ពេលស្អែកឡើងចឹងទៅគេបានមកយកម្នាក់នឹងទៅរស់នៅកោះឧកញ្ញាតីចឹងទៅហាសចាសហើយសំរាប់បងប្អូនរបស់យើងនឹងមិនដឹងថាគេនឹងបានគិតយ៉ាងមិចនោះទេអោយតែបងប្អូនបង្កើតនឹងគឺគេមិនបានអោយយើងនឹងបានរស់នៅជាមួយនឹងគ្នានោះទេចាសហើយសំរាប់នាក់ខ្លះនឹងគឺគេបានលាក់ចឹងហាសពីព្រោះអីនឹងគឺគេមិនចង់បែកពីបងប្អូនរបស់គេចឹងហាសចាសហើយប្រសិនជាមួយថ្ងៃនឹងគឺគេនឹងមិនប្រាប់នោះទេចាស៕

កៈ
បាទហើយចឹងសំរាប់គេធ្វើយ៉ាងមិចដែលបានជាបានដឹងថាយើងនឹងគឺជាប?ងប្អូននឹងគ្នាចឹងទៅអ្នកមីង???

ខៈ
ចាសនិយយាទៅអោយតែយើងនឹងមានភាពសិទ្ធិស្នាលនឹងហើយមានអ្វីនឹងបានចែកគ្នាហូបចឹងទៅហើយបានប្រាប់គ្នាយើងនឹងបាននឹងកម្ដាយហើយនឹងនឹកឪពុកចឹងហាសចាសហើយនិយយាទៅអោយតែយើងនឹងនិយាយគ្នួយហាសហើយសំរាប់នាក់ដែលបានរស់នៅជាមួយនឹងគឺគេយកមុខចឹងហាសគឺវានឹងបានទៅរាយការណ៍ហើយចាសហើយដល់ពេលដែលគេរាយការណ៍ហើយចឹងជូននឹងហើយយើងនឹងបាននិយាយយើងនឹងបាននឹកម្ដាយយើងនឹងណាស់គ្រាន់តែនិយាយបិននឹងគឺគេបានដឹងតែម្ដងហាសថាយើងនឹងគឺជាបងប្អូនហើយចាសក្នួយហើយសំរាប់នាក់ដែលមិននឹកម្ដាយមិនចឹងហើយនៅពេលដែលយើងនឹងបានដេកនៅជាមួយនឹងគ្នាចឹងទៅគឺយើងនឹងបានរំលឹកថាយើងចឹងទៅហើយនិយាយអំពីម្ដាយរបស់យើងចឹងទៅហើយមានគេនឹងបានសំឡឹងមកយើងចឹងទៅហើយយើងនឹងមិនបានដឹងថាគេបានគិតមកយើងនឹងវាយ៉ាងមិចទេហាសចាសហើយដូចថានឹងហើយគឺជាភ្នែកហើយនឹងត្រជៀកនឹងហាសចាសហើយដល់ពេលដែលយើងនឹងបាននិយាយទៅគឺវាកាត់យើងនឹងបានជាប់ចឹងហើយសំរាប់បងហើយនឹងប្អូននឹងហើយនឹងពូហើយនឹងមៀលនឹងគឺមិនអាចជួបគ្នានោះទេចាសហើយសំរាប់នាក់កាន់នៅខាងនឹងចឹងទៅគឺគេបានកាន់មួយចំហៀងនៅខាងកោះចឹងទៅហាសចាសនិយាយទៅគឺវាម្នាក់មួយចំហៀងចឹងទៅចាសហើយសំរាប់សហារក៏របស់គេ១នឹងបាននៅមួយកន្លែងចឹងទៅហើយសំរាប់សហារក៏របស់គេ១នឹងបាននៅមួយកន្លែងចឹងទៅចាស៕

កៈ
បាទហើយចឹងប្រសិនជាយើងមិនចង់អោយគេបានដឹងថាយើងនឹងគឺជាបងប្អូននឹងគ្នានឹងយើងមិនបាច់និយាយទាំងអស់នោះទេមែនដែលទេអ្នកមីង???

ខៈ
ចាសនិយាយទៅគឺយើងមិនបាច់និយាយអ្វីនោះទេហើយយើងនឹងធ្វើជាមិនដឹងអីចឹងទៅហាសចាសហើយគ្រាន់តែយើងនឹងនឹកបងហើយនឹងនឹកប្អូនរបស់យើងចឹងហាសចាសហើយប្រសិនជាយើងនឹងបានឃើញបងប្អូនរបស់យើងចឹងគឺយើងធ្វើការងាររបស់យើនឹងរៀងរៀនខ្លួនចឹងទៅគឺយើងធ្វើជាមិនស្គាល់គ្នាចឹងហាសចាសហើយប្រសិនជានៅក្នុងសហារករនឹងគឺបានបានដឹងថាយើងនឹងគឺជាបងប្អូននឹងគ្នានឹងហើយមានគេបានទៅប្រាប់ថាយើនឹងយើងនឹង២នាក់នឹងគឺបងប្អូននឹងគ្នាចឹងទៅគឺគេនឹងចាប់យើងនឹងបំបែកដែលចឹងហាសចាសហើយអោយតែមាននាក់ដែលនៅក្នុងនឹងគឺគេបានដឹងថាយើងនឹងគឺជាបងប្អូននឹងគឺគេបាននិយាយប្រាប់ចឹងហាសចាសគឺតែបានបំបែកយើងហើយចាស៕

កៈ
បាទហើយចឹងនៅពេលដែលម្នាក់ដែលគេបានដឹងហើយគេបានទៅប្រាប់អង្គការចឹងថាយើនឹងគឺគេបងប្អូននឹងគ្នាចឹងហើយនៅពេលដែលគេបានប្រាប់ចឹងហើយសំរាប់ម្នាក់នឹងថាតើគេបានរង្វាល់រឺក៏គេបានទោសដែលទៅអ្នកមីង???

ខៈ
ចាសនិយាយទៅគឺកគ្មានបានរង្វាល់អ្វីនោះទេចាសនិយាយទៅគ្រាន់តែបានមុខហើយនឹងបានមាត់តែប៉ុននឹងចឹងហាសហើយនៅពេលដែលគេបានធ្វើការងារយូរយូរទៅគឺគេបានអោយម្នាក់នឹងបានធ្វើការងារជាប្រធានក្រុមចឹងទៅហាសចាសហើយគ្រាន់តែប្រាប់ថាម្នាក់នេះធ្វើការងារនៅទីកន្លែងនេះហើយសំរាប់ម្នាក់សំរាប់ម្នាក់នោះត្រូវធ្វើការងារនៅទីកន្លែងនោះចឹងហាសចាសហើយគ្រាន់តែថាគេនឹងបានធ្វើការងារបានធូរកំលាំងចឹងហាសចាសហើយគ្រាន់តែបានឡើងធ្វើជាអ្នកគ្រប់គ្រងមើលការខុសត្រូវអីចឹងហាសចាសដែលនៅក្នុងសហាករណ៏ដែលនៅក្នុងក្រុមដែលនៅកន្លែងកុមារចឹងហាសចាសគ្រាន់តែគេនឹងចង់យកមុខនឹងចឹងចាសគ្រាន់តែគេបានមើលការខុសហើយនឹងត្រូវចឹងហាសនិយយាទៅបានមើលមួយកន្លែងមួយកន្លែងហើយនឹងមួយសហាករចឹងទៅគឺគេបានបិននឹងហាសក្អួយហើយដល់ពេលចឹងគឺគេបានប្រឹងហើយគឺប្រឹងអេបហើយខំចឹងទៅហាសហើយសំរាប់នាក់ដែលមិនបានធ្វើតាមគេនឹងគឺគេបានយកយើងនឹងទៅកសាងចឹងហាសរួចហើយចាសហើយមានពេលខ្លះនឹងគឺយើងនឹងពិបាក់សំរាប់នាក់ដែលយកមុខចឹងហាសចាសហើយសំរាប់យើងនឹងបានបែកបាក់គ្នានឹងក៏ដោយសារចឹងដែលហើយសំរាប់ចេកហើយនឹងស្វាយដែលនៅមានមុខផ្ទះរបស់យើងនឹងបេះហូបតែ១ហើយនឹង២ចឹងហាសគឺពួកវានឹងយកយើងនឹងទៅកសាងហើយចាសហើយសំរាប់ស្វាយរបស់យើនឹងសោះហាសបេះមិនបានហើយសំរាប់មួយសប្តាហ៏ចឹងទៅគឺពួកវានឹងបានដើលបេះទៅតាមផ្ទះចឹងទៅហើយយកមកដាក់តាមសហាករហើយយើងនឹងបានសួរសហាករនឹងយកទាំងអស់នឹងទៅណាហើយគេបាននិយាយថាគឺគេបានប្រមូលទាំងអស់នឹងយកទៅអោយអ្នកដែលនៅធ្វើការងារចឹងហាសចាសហើយសំរាប់យើងនឹងក៏មិនបានដឹងដែលចឹងហាសសំរាប់គេយកទៅណានឹងក៏យើងនឹងមិនបានដឹងដែលហាសចាសហើយសំរាប់យើងនឹងនៅពេលដែលគេបេះនឹងគឺយើងនឹងបានត្រឹមតែអង្គុយមើលគេបេះចឹងហាសហើយសំរាប់ស្វាយដែលទុំនឹងគឺគេបានបេះដាក់ទាំងរទេះគោទាំងរទេះគោចឹងហាសចាស៕

កៈ
បាទហើយចឹងយ៉ាងមិចដែលបានជាគេមិនបានអោយយើងនឹងបានបេះចឹងពីព្រោះអីនឹងទាំងអស់នឹងគឺជាយើងនឹងជាដាំសោះចឹងហាសអ្នកមីង???

ខៈ
ចាសនិយាយទៅគឺគេមិនបានអោយយើងនឹងបានបេះនោះទេគឺគេបាននិយាយថាទាំងអ

ស់នឹងគឺគេមិនអោយយើងនឹងបានហូបជាឯកជននោះទេចាសហើយសំរាប់សមរភាពនឹងនៅពេលដែលគេបានបេះហើយចឹងទៅគឺគេបានអោយយើងនឹងបានហូបបបរហើយចឹងគឺគេបានអោយយើងនឹងបានបេះហើយបានចែកគ្នានឹងបានហូបទាំងអស់ចឹងហាសចាសហើយនិយាយទៅគឺគេបានអោយយើងនឹងសាមគ្គីគ្នានឹងហើយគឺជាសមរភាពរួមនឹងហាសចាសហើយមានអ្វីគឺអោយយើងនឹងបានហូបទាំងអស់គ្នាហើយសំរាប់របស់យើងហើយសំរាប់យើងនឹងគឺគេមានគ្រប់ផ្ទះហើយសំរាប់ពួកវានឹងមិនបានអោយយើងនឹងដែលនៅតាមផ្ទះនឹងអោយបានហូបខ្លួនឯងចឹងទៅហាសនិយាយទៅគឺវាមិនបានអោយយើងនឹងបានហូបតែម្តងហើយសំរាប់ស្វាយទាំងរទេះរទេះមិនដឹងគេយកទៅណានោះទេចាសហើយនិយាយទៅគឺគេចង់អោយយើងនឹងបានហូបជាសមរភាពគឺគេមិនអោយយើងនឹងបានហូបដោយឯកជនចឹងហាសចាសហើយសំរាប់ដំណាំទាំងអស់នឹងគឺគេយកទៅណាតាមតែចិត្តគេចឹងហាសហើយគ្មានសមភាពណានោះទេគឺមានតែពួកនឹងហើយចឹងហាសហើយសំរាប់ពួកវានឹងបាននិយាយថាគឺអង្គការនឹងបានដឹកទុក្ខសំរាប់យើងចឹងហាសចាសហើយសំរាប់យើងនឹងទុកនៅកន្លែងណាក៏បានដែលចឹងហាសចាសហើយពួកវានឹងបានដាក់នៅក្នុងបារនឹងហើយអង្គការនឹងបានដាក់ទុក្ខហើយពួកវាបាននិយាយថាទាំងអស់នឹងគឺទុក្ខសំរាប់ប្រជាជននឹងសំរាប់ហូបហើយសំរាប់អ្នកខ្លះណាដែលគេមានកង់ហើយនឹងម៉ូតូចឹងហាសគឺគ្មាននោះទេចាស៕

ក៖
បាទហើយចឹងសំរាប់នៅក្នុងជំនាន់នឹងថាតើនៅពេលដែលគេដាំហើយនឹងផ្លែឈើហើយនៅពេលដែលគេយកទៅគឺដើម្បីចែកអោយពួកនាក់ដែលធ្វើសង្គ្រាមមែនដែលទេអ្នកមីងហើយសំរាប់អ្នកមីងមានដឹងថាគេមានសង្គ្រាមដែលរឺទេអ្នកមីង???

ខ៖
ចាសហើយសំរាប់សង្គ្រាមនឹងសំរាប់យើងនឹងយើងទៅដឹងអ្វីទៅក្មួយហើយពួកវានឹងបានអាងតែពួកវានឹងបានធ្វើខុសអូនឹងទាហ៊ានរបស់នឹងវាបានក្បួងហើយនឹងយកទៅសំលាប់យើងចោលចឹងហាសហើយសំរាប់ពួកវានឹងបានធ្វើយើងនឹងដូចជាសត្វគោហើយនឹងសត្វធាតុចឹងហាសចាសហើយសំរាប់កាំភ្លើងនឹងបានចឹងគឺវាអោយយើងនឹងទៅរែកដីចឹងហាសហើហាយមាន២នាក់៣រចឹងទៅហើយសំរាប់ទាហ៊ានរបស់វានឹងមាន១នាក់ចឹងហាសចាសហើយពួកនឹងនៅឈរចាំមើលយើងចឹងហាសខ្លាចយើងនឹងមិនបានធ្វើការងារចឹងហាសចាសនឹងសំរាប់ទាហ៊ាននឹងរបស់វានឹងគឺចឹងហាសចាស៕

ក៖
បាទហើយសំរាប់ទាហ៊ានពោលពតនឹងខ្ញុំបានលឺចាស់ចាស់គាត់បាននិយាយថាគឺគេមិនមែនជាមនុស្សចាស់ចាស់នោះទេមែនដែលគឺពួកទហ៊ាននឹងគឺជាក្មេងក្មេងមែនដែលទេអ្នកមីង???

ខ៖

ចាសនិយាយទៅទហ៊ាននឹងគឺជាក្មេងក្មេងទេហើយសំរាប់ពួកវានឹងហូសកាំភ្លើងនឹងមិនចង់នឹងរួចផងនឹងហាសចាសហើយនៅពេលដែលគេបានយកយើងនឹងទៅ៣ដងហើនឹង៤ដងចឹងហើយយើងនឹងមិនធ្វើការងារចឹងគឺគេនឹងយកយើងនឹងទៅបាញ់ចោលហើយហើយសំរាប់ក្មេងនឹងគ្រាន់តែហូសកាំភ្លើងនឹងក៏អូសមិនចង់ដល់ដីដែលចឹងហាសតែសំរាប់ពួកគេនឹងមកបញ្ចូលដែលយើងនឹងជាចាស់ចាស់ធ្វើការងារចឹងហាសចាសហើយប្រសិនជាយើងនឹងមិនធ្វើការងារវានឹងសំលាប់យើងចោលចាស៕

ក៖

បាទហើយចឹងខ្ញុំឆ្ងល់ថាហេតុអ្វីបានជាក្មេងដែលពួកគាត់មិនសូវមានកំលាំងហើយស្ពាយកាំភ្លើងនឹងអូសមិនដល់ដីផងនឹងហើយនឹងហើយប្រជាជននៅក្នុងជំនាន់នឹងហេតុអ្វីបានជាពួកគាត់មិនហ៊ានធ្វើអ្វីដល់ក្មេងក្មេងនឹងចឹងអ្នកមីង???

ខ៖

ចាសនិយាយទៅកាល់នៅក្នុងជំនាន់នឹងគឺយើងទាំងអស់គ្នាខ្លាចអំណាចរបស់គេចឹងហាសចាសហើយសំរាប់ក្មួយឯងគិតមើលមើលថាសំរាប់ក្មេងនឹងមួយជួរចឹងហាសនៅពេលដែលយើងនឹងបានកំពុងតែរ៉ែកដីចឹងហាសគឺវាបានឈរបញ្ជាយើងនឹងហើយវាបាននិយាយថាយើងនឹងក្រោកឡើងហើយធ្វើអានេះធ្វើអានោះចឹងហាសចាសហើយដល់ពេលដែលយើងនឹងអត់មិនបានចឹងក៏យើងនឹងបានតរដាក់វាវិញចឹងហាសហើយប្រសិនជាយើងនឹងជាមនុស្សចាស់វិញចឹងហាសគឺយើងនឹងបានហៅវានឹងជាបងវិញដែលយើងនឹងជាមនុស្សហើយយើងនឹងត្រូវហៅវាក្មេងជាបងចឹងហាសចាសហាចាសហើយនៅពេលដែលយើងនឹងហៅវានឹងហៅចឹងហើយយើងនឹងមិចនឹងព្រមចឹងហាសហើយដល់ពេលចឹងហើយបានជាយើងនឹងគ្មានការងារអីនឹងហើយយើងនឹងនិយាយអ្វីដែលមិនល្អចឹងគឺគេនឹងសំលាប់យើងនឹងចោលភ្លែមតែម្តងហាសចាសចឹងហើយបានជាម្នាក់នឹងគ្មានកំលាំងនឹងតរទាលនឹងពួកវាចឹងហាសចាសហើយសំរាប់ម្នាក់ម្នាក់នឹងគឺគេបានដើរនឹងទាំងគ្មានកំលាំងផងចឹងហាសហើយយើងនឹងគ្មានអ្វីនឹងបានហូបគ្រាប់គ្រាន់ចឹងហើយយើងនឹងគ្មានកំលាំងមកពីណាដើម្បីនឹងតរទាល់នឹងពួកវាចឹងហាសហើយសំរាប់ពួកវាវិញពួកវានឹងគឺក្មេងក្មេងតែកំលាំងរបស់ពួកវានឹងគឺខ្លាំងខ្លាំងណាស់ចាសពីព្រោះអីនឹងពួកវានឹងហូបឆ្អែតហាសហើយសំរាប់យើងនឹងហូបបានតែបបរចឹងហាសចាសចឹងហើយមានកំលាំងនឹងបានមកពីណាចឹងហើយតាមដំណាងចឹងទៅហាសហើយសំរាប់នាក់ណាដែលគេហ៊ានតចឹងគឺគេសំលាប់ចោលនៅទីកន្លែងនឹងតែម្តងហាសចាសនិយាយរួមទៅអោយតែតគឺពួកវានឹងសំលាប់យើងចោលលចឹងហាសចាសចឹងហើយបានជាម្នាក់ម្នាក់នឹងគឺខ្លាចរៀងរៀងខ្លួនចឹងហាសចាស៕

ក៖

បាទហើយចឹងខ្ញុំឆ្ងល់ថាប្រសិនជាមានមនុស្សច្រើនចឹងហាសពីព្រោះអីនឹងកាល់នៅក្នុងជំ

នាន់នឹងគឺវាមានមាឌនឹងតូចដែលចឹងហាសហើយប្រសិនជាយើងនឹងមានគ្នាច្រើនហើយមានមនុស្សនឹងរាប់មឺននាក់ចឹងគឺយើងនឹងធ្វើបានមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺវាចេះប្រសិនជាយើងនឹងធ្វើគឺវានឹងឈ្នះហើយតែវាសំរាប់យើងនឹងគឺយើងនឹងវាមិនហ៊ានចឹងហាសចាសគឺមិនហ៊ាននឹងអង្គការចឹងហាសនិយាយទៅគឺយើងនឹងចង់បានតែយើងនឹងមានរស់រានមានជីវិតចឹងហាសចាសសំរាប់នៅក្នុងជំនាន់នឹងហើយអោយតែបានមានជីវតនឹងបានរស់នឹងនៅថ្ងៃណាហើយសំរាប់គេបានមកជួយថ្ងៃណាគឺយើងនឹងគិតទៅថ្ងៃនឹងចឹងហាសចាសនឹងចឹងហាសហើយសំរាប់ជំនាន់ពោលពតប្រសិនជាយើងនឹងសំលាប់គ្នារបស់ពួកវានឹងគឺវានឹងសំលាប់យើងនឹងមួយពូជចឹងហាសហើយសំរាប់ពួកវានឹងគឺពួកវានឹងបានស្រាវជ្រាវតាមខ្សែរយះរបស់គ្រួសាររបស់យើងនឹងតែម្តងហាសចាសហើយនៅពេលដែលគេបានស្រាវជ្រាវឃើញហើយចឹងគឺវានឹងសំលាប់គ្រួសាររបស់យើនឹងមួយពូជតែម្តងហាសចាស៕

ក៖
បាទហើយចឹងបានន័យថាប្រសិនជាយើនឹងហ៊ានតែធ្វើបាបកូនទាហ៊ាននឹងគឺគេនឹងយកយើងនឹងសំរាប់ទាំងមួយពូជតែម្តងមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺគេនឹងសំរាប់យើងទាំងមួយពូជចោលម្តងហាសនៅពេលដែលគេបានស្រាវជ្រាវនាក់ណាដែលបានធ្វើបាបកូនទាហ៊ានរបស់គេចឹងហាសចាសគឺគេនឹងចង់ទាំងខ្សែទាំងខ្សែហើយនឹងមានរណ្តៅរបស់គេនឹងហាសហើយសំរាប់រណ្តៅរបស់គេនឹងនៅពេលដែលយើងនឹងបានមើលទៅហាសគឺដាច់កន្ទុយភ្នែករបស់យើងចឹងហាសចាសហើយសំរាប់រណ្តៅរបស់វានឹងនៅពេលដែលយើងមើលទៅគឺមានជំរៅនឹងគឺជ្រៅខ្លាំងណាស់ចាសហើយនិយាយទៅគឺគួរខ្លាចណាស់ហើយនៅពេលដែលយើងនឹងតជាមួយពួកតែមួយនឹងគឺយើងនឹងស្លាប់ទាំងអស់ចឹងហាសហើយចឹងនៅពេលដែលគែបានរាយការណ៌ទៅប្រាប់មេរបស់វាចឹងហាសហើយយប់នឹងមួយគ្រួសារនឹងនឹងមិចបាច់រស់នោះទេគឺគេនឹងយកទៅសំលាប់ទាំងចឹងហាសចាសនិយាយរួមទៅទាំងបងបង្កើតហើយបងជីដូនមួយហើយនឹងជីដូនហើយនឹងជីតានិយាយទៅមួយខ្សែនៅក្នុងគ្រួសាររបស់យើងនឹងហាសចាសហើយមីងហើយនឹងពូនឹងគឺស្លាប់ទាំងអស់ហាសចាសហើយនិយាយទៅគឺស្លាប់ទាំងម្តងហាសចាសហើយទោះបីជាយើងនឹងមិនបានដឹងរឿងនឹងអ្វីក៏ដោយក៏ពួកវានឹងយកយើងនឹងទៅសំលាប់ចោលទាំងមួយពូជដែលចឹងហាសចាសហើយដូចថាយើងនឹងបានសំលាប់ទព្វ័របស់ចឹងហាសហើយរឺក៏ជាអង្គការរបស់គេចឹងហាសអោយគេបានដឹងចឹងហាសគឺគេនឹងយកយើងនឹងទៅសំលាប់ចោលហើយចាសហើយចឹងហើយបានជាយើងនឹងចេះតែខ្លាចហើយនឹងមិនហ៊ានធ្វើអ្វីនឹងគឺចឹងហាសចាសហើយសំរាប់គេបានដាក់ជាទាហ៊ាននឹងបាន៤រឺក៏៥នាក់ចឹ

ងហាសហើយពួកយើងនឹងបានសង្កត់មកចឹងហាសហើយប្រសិនជាយើងនឹងបានដាក់តែមួយម្នាក់មួយដៃហើយនឹងមួយជើងនឹងក៏ងាប់ដែលចឹងហាសចាសតែយើងនឹងគ្រាន់តែថាយើងខ្លាចនឹងអំណាចរបស់គេចឹងហាសហើយនិយាយទៅយើងខ្លាចតែយើងនឹងបានសំលាប់វានឹងបានតែមួយម្នាក់ចឹងគឺយើងនឹងត្រូវស្លាប់ទាំងអស់មួយពូជចឹងតែម្តងហាសចាសចឹងហើយបានជាយើងនឹងចេះតែធ្វើខ្លាចហើយនឹងធ្វើជាចាញ់គេចឹងហាសចាស៕

ក៖
បាទហើយចឹងបានន័យថាជាមូលហេតុដែលយើងនឹងមិនហ៊ានតទាល់នឹងជាមួយកូនទាហ៊ានចឹងមែនដែលទេងអ្នកមីងបាទហើយចឹងអរគុណច្រើនអ្នកមីងហើយចឹងខ្ញុំចង់សួរទៅកាន់អ្នកមីងមួយទៀតថាតើអ្នកមីងមានបានដឹងទេថាតើនៅក្នុងជំនាន់ណាដែលរឺក៏ឆ្នាំណាដែលដែលគេបានចូលមកជួយរំដោះប្រជាជនខ្មែររបស់យើងនឹងនៅក្នុងជំនាន់ណាដែលទៅអ្នកមីងបាទដែលបែកពីជំនាន់ពោលពតមកហើយចឹងហាសចាសថាតើអ្នកមីងមានដឹងដែលទេអ្នកមីង???

ខ៖ ចាសនៅពេលដែលបែកជំនាន់ពោលពតនឹងគឺគេបានមកជួយរំដោះនឹងនៅក្នុងឆ្នាំ ១៩៧៩ ហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានបែកនៅក្នុងជំនាន់ពោលពតនឹងហើយចឹងថាតើសំរាប់អ្នកមីងបានរត់ទៅទីកន្លែងណាដែលទៅអ្នកមីង???

ខ៖
ចាសនៅពេលដែលខ្ញុំបានបែកពីជំនាន់ពោលពតហើយចឹងគឺខ្ញុំបានរត់ទៅនៅកន្លែងនឹងដ៏ដែលចឹងហាសគឺគ្មានទៅកន្លែងណានោះទេគឺនៅកោះឧកញ្ញាតីនឹងតែម្តងហាសហើយសំរាប់ខ្ញុំគឺគ្មានបានទៅខាងបាត់ដំបងហើយនឹងពោធ៏សាត់អីនឹងគេគឺគ្មាននោះទេចាសក្មួយហើយសំរាប់ខ្ញុំនឹងបានរស់នៅខាងកោះដាច់ដែលនៅខាងល្វានឹងហាសហើយយើងបានជីកហើយនឹងទប់ប្រឡាយហើយនឹងទន្លេរចឹងហាសហើយសំរាប់ពោលពតនឹងគឺខ្ញុំនឹងបានរ៉ែកហើយនឹងធ្វើការងារច្រើនចឹងហាសចាស៕

ក៖
បាទតែសំរាប់ខ្ញុំបានលឺចាស់ចាស់គាត់បាននិយាយថានៅពេលដែលបែកពោលពតហើយចឹងហើយដែលគេចូលជិតមករំដោះចឹងថាតើពួកពោលពតនឹងថាតើគេមានបានពីធីជុបលាងអោយប្រជាជនដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់កន្លែងរបស់ខ្ញុំនឹងគឺគ្មាននោះទេចាសតែសំរាប់កន្លែងរបស់គេផ្សេងនឹងគឺគេមាន

ចឹងហាសចាសហើយសំរាប់កន្លែងរបស់ខ្ញុំនឹងគឺគ្មាននោះទេសំរាប់ពីធីចឹងហាសចាសក៏ប៉ុន តែនឹងសំរាប់កន្លែងរបស់ខ្ញុំនឹងមានសុទ្ធតែពួកពោលពតចឹងហាសចាសហើយនឹងមានកាំ ភ្លើងនឹងដែលគេបានបាញ់ទៅខាងភ្នំពេញចឹងហាសចាសហើយគ្រាន់តែគេបានលឺថានៅ ពេលដែលយើងនឹងបានបែកហើយនឹងបានចប់នៅក្នុងជំនាន់ឆ្នាំ ១៩៧៩
នឹងហើយចឹងហាសចាសគឺយើងនឹងគ្មាននឹងបានដើរតាមផ្លូវនឹងនោះទេគឺយើងនឹងបានដើរ តាមផ្លូវដែលនៅខាងក្រោយតាមផ្ទះរបស់យើងចឹងហាសចាសហើយសំរាប់ផ្លូវនឹងគឺយើង មានតែផ្លូវនឹងគឺវាតូចចឹងហាសសំរាប់ដើរតាមនឹងចឹងហាសចាសនឹងហើយគឺជាផ្លូវរបស់ យើងចឹងហាសដែលដើរតាមនឹងហាសចាស៕

ក៖
បាទហើយចឹងបានន័យថាសំរាប់ពីធីសំរាប់ជុនលៀងសំរាប់ប្រជាជននៅខាងអ្នកមីងគឺគ្មាន នោះទេមែនដែលទេអ្នកមីង???

ខ៖
ចាសនិយាយទៅគឺមានដែលគឺមានមួយម្ដងហាសចាសហើយនៅពេលដែលមានគឺមានជា លក្ខណះជាសិល្ប៍ះចឹងហាសចាសហើយនៅពេលនឹងគឺមានប្រជាជននឹងបានទៅមើលចឹ ងហាសចាសហើយនឹងគឺមានមែនចឹងហាសនៅពេលដែលក្មួយឯងនឹងបាននិយាយចឹង ហាសគឺខ្ញុំនឹងបានចាំគឺនៅពេលនឹងគឺគេបានហៅថាយើងនឹងបានទៅជុបលៀងចឹងហាស ចាសហើយគេបានហៅសិល្បះនឹងបានអោយគេបានលេងចឹងហាសចាសហើយសំរាប់ក្មួ យឯងនឹងមានបានដឹងទេហើយសំរាប់ចំហៀងដែលនៅខាងនោះហើយនឹងចំហៀងដែល នៅខាងនេះនឹងគឺមើលទៅសុទ្ធតែរណ្ដៅទាំងអស់ចឹងហាសចាសហើយនៅពេលនឹងគឺគេ មានខ្សែភ្លើងនឹងយកមកជុំចឹងហាសចាសហើយដល់ពេលនឹងក៏មានខ្យលហើយនឹងមាន ភ្លៀងមកដែលបានធ្លាក់ដែលចឹងហាសចាសហើយសំរាប់ពេលនឹងគឺប្រជាជននឹងបានភ្ញើ លហើយក៏បានរត់ចែកជើងគ្នាចឹងហាសចាសហើយសំរាប់ការរត់នឹងមើលប្រហែលជាខ្វង់ ២ខែចឹងហាសចាសហើយបានគេនឹងបានបាក់ចឹងហាសចាសដែលគេបានចូលមកហើយ នឹងបានរំដោះហើយចឹងហាសចាសដល់ពេលនឹងហើយបានយើងនឹងបានរស់រានមានជីវិត នៅក្នុងឆ្នាំ ១៩៧៩
ចឹងហាសចាសនឹងហើយបានមកដល់លូវនឹងហាសក្មួយហើយនឹងបានមកដល់លូវនឹងបា នសុខសប្បាយមកដល់លូវនឹងហាសក្មួយចឹងទៅហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលអ្នកមីងបានរត់បែកពីជំនាន់ពោលពតហើយចឹងហាសហើយ សំរាប់អ្នកមីងបានារត់គេចនៅនឹងពីធីជុបលៀងនឹងហាសហើយសំរាប់អ្នកមីងនៅពេលដែ លអ្នកមីងបានរត់ចេញហើយចឹងហើយសំរាប់អ្នកមីងបានរត់មកជាមួយនឹងគ្រួសាររបស់អ្ន កមីងរឺក៏បានរត់មកជាមួយនឹងនាក់គេដែលទៅអ្នកមីង???

ខ៖

ចាសនៅពេលដែលខ្ញុំនឹងបានរត់មកចឹងគឺខ្ញុំបានរត់មកជាមួយនឹងក្រុមគ្រួសាររបស់ខ្ញុំហាសចាសហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងហើយនឹងឪពុកហើយនឹងម្ដាយហើយនឹងពូហើយនឹងមីងរបស់ខ្ញុំនឹងគឺមកជុំគ្នាចឹងហាសចាសហើយសំរាប់នាក់ខ្លះនឹងគឺគេបានជំលាស់នឹងទៅដល់គ្រៀនស្វាយចឹងហាសហើយយើងនឹងបានដើរមកជុំគ្នាជាមួយនឹងគ្នាចឹងហាសចាសហើយយើងនឹងបានបោះអីចឹងអោយបានស្អាតហើយយើងនៅមួយរយះសិនទៅចឹងហាសចាសហើយប្រសិនជាគេមានផ្ទះសំរាប់នៅចឹងទៅហើយប្រសិនជាយើងមានផ្ទះចឹងគឺយើងនៅផ្ទះចឹងទៅហាសហើយសំរាប់ម្ដាយមីងរបស់ខ្ញុំនឹងហើយផ្ទះរបស់គាត់នឹងគឺគាត់នឹងបានរស់នៅចឹងហាសចាសហើយសំរាប់ផ្ទះណាដែលល្មមនឹងគឺគេបានយកអស់ហើយចឹងហាសចាសហើយសំរាប់យើងនឹងបានមកវិញនឹងគឺយើងនឹងបានមករស់នៅចឹងទៅហាសនឹងសំរាប់ផ្ទះម្ដាយមីងរបស់ខ្ញុំនឹងហាសចាសហើយសំរាប់ម្ដាយមីងរបស់ខ្ញុំនឹងគឺគាត់បានរស់នៅចឹងហាសចាសហើយសំរាប់នាក់ខ្លះនឹងគឺគេបានរសរោងនឹងហើយទៅធ្វើរោងនឹងកន្លែងផ្សេងចឹងទៅហាសចាសហើយសំរាប់លូវនឹងទើបតែបានធ្វើបានស្អាតជាមុខតិចចឹងហាសចាស៕

ក៖

បាទហើយហេតុអ្វីដែលបានជាគេរុសហើយហើយគេបានយកមកទុក្ខចោលចឹងអ្នកមីង???

ខ៖

ចាសនិយាយទៅគឺខ្ញុំនឹងមិនបានដឹងយ៉ាងមិចដែលចឹងហាសចាសពីព្រោះអីនឹងគឺបាយនឹងគឺជាបាយសហាករណ៏ចឹងហាសហើយនៅពេលដែលយើងបានធ្វើចឹងគឺបានហូបបាយសហាករណ៏ចឹងតែម្ដងហាសហើយសំរាប់ផ្ទះណាដែលគេមានផ្ទះដែលតូចតូចនឹងគឺគេបានជំលាស់អស់ចឹងហាសចាសហើយនៅពេលដែលបានរើសអស់ហើយចឹងគឺគេបានយកធ្វើអូសសំរាប់ដុតចឹងហាសចាសចឹងហាសក្មួយហាសចាសហើយសូម្បីតែកងមួយនឹងក៏គេមិនបានទុក្ខអោយយើងចឹងហាសចាស៕

ក៖

បាទហើយចឹងអរគុណាច្រើនអ្នកមីងចឹងខ្ញុំចង់សួរសំណួរអ្នកមីងមួយទៀតថាតើនៅពេលដែលគេបានរត់បានចេញពីជំនាន់ពោលពតហើយចឹងហើយសំរាប់អ្នកមីងបានមករត់រស់នៅទីកន្លែងនឹងគឺជាកោះឧកញ្ញាតីនឹងថាតើសំរាប់អ្នកមីងមានអារម្មណ៏យ៉ាងមិចដែលនៅពេលដែលអ្នកមីងបានបែកពីជំនាន់ពោលពតហើយចឹងហាសចាសអ្នកមីង???

ខ៖

ចាសនិយាយទៅនៅពេលដែលបានបែកពីជំនាន់ពោលពតហើយចឹងគឺខ្ញុំមានអារម្មណ៏ថាសប្បាយចិត្តហាសហើយខ្ញុំនឹងក៏បាននឹកឃើញដែលថាអារម្មណ៏ដែលយើងនឹងបានស្លាប់

ហើយចឹងហើយយើងនឹងបានរស់ឡើងវិញម្តងទៀតចឹងហាសក្មួយហើយសំរាប់ភាពអរសប្បាយគឺមានភាពសប្បាយខ្លាំងណាស់និយាយទៅគឺអរខ្លាំងណាស់ក្មួយហើយនិយាយទៅដូចថាយើងនឹងបានងើបឡើងពីនរកចឹងហាសចាសហើយយើងនឹងបានស្លាប់ហើយរស់ឡើងវិញចឹងហាសចាសនិយាយទៅគឺថាដូចយើងនឹងបានរស់ឡើងវិញម្តងទៀតចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបាននឹកឃើញសំរាប់ជំនាន់ពោលពតនឹងហាសគឺខ្ញុំឆ្អែតតែម្តងហាសចាសហើយសំរាប់ខ្ញុំនឹងមិននឹកស្មានថាខ្ញុំមានជីវិតរស់មកដល់សព្វថ្ងៃនឹងទេហាសចាសគឺខ្ញុំមិននឹកស្មាននោះទេចាស៕

ក៖
បាទហើយចឹងអរគុណច្រើនមែនទែនអ្នកមីងហើយសំរាប់ថ្ងៃនឹងគឺសប្បាយចិត្តមែនទែនអ្នកមីងដែលអ្នកមីងបានផ្តល់ហើយនឹងបានពិភក្សាអំពីជីវិតពិតរបស់អ្នកមីងចឹងហាសដែលជីវិតរបស់អ្នកមីងបានរស់នៅក្នុងជំនាន់អ្នកមីងហើយសំរាប់ថ្ងៃនឹងក៏ខ្ញុំមានអារម្មណ៍ថាសប្បាយចិត្តដែលបានជួបជាមួយនឹងអ្នកមីងផ្ទាល់ហើយចឹងសំរាប់លូវនឹងគឺខ្ញុំមានសំណួរមួយចុងក្រោយចង់សួរទៅកាន់អ្នកមីងគឺជាសំណួរចុងក្រោយហាសថាតើសំរាប់អ្នកមីងមានអ្វីសំរាប់ផ្តែលផ្តាំទៅកាន់កូនចៅរបស់អ្នកមីងដែលរឺទេនៅពេលដែលពួកគាត់បានលឺសំលេងហើយនឹងពេជ្ររបស់អ្នកមីងដែលនៅក្នុងសំលេងមួយនេះចឹងហាសថាតើអ្នកមីងមានផ្តែលផ្តាំទៅកាន់គាត់ដែលរឺទេដើម្បីអោយពួកគាត់ហើយនឹងបានរំលឹកនៅពេលដែលអ្នកមីងបានរស់នៅក្នុងជំនាន់ពោលពតនឹងអ្នកមីងដែលមានជីវិតលំបាកអ្វីខ្លះដើម្បីអោយពួកគាត់អោយបានកូនចៅរបស់ពួកគាត់នៅជំនាន់ក្រោយទៀតថាតើសំរាប់អ្នកមីងមានអ្វីសំរាប់ផ្តែលផ្តាំទៅកាន់គាត់ដែលរឺទេអ្នកមីង???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមិនជាសូវចេះផ្តែលផ្តាំនោះទេតែគ្រាន់តែផ្តែលផ្តាំថាសូមអោយពួកគាត់នឹងបានសុខសប្បាយហើយនឹងហើយសំរាប់យើងនឹងធ្វើអ្វីមួយនឹងសូមអោយវានឹងបានស្រប់ច្បាប់ចឹងហាសចាសហើយកុំអោយដូចនៅក្នុងជំនាន់ពោលពតចឹងហាសគឺគ្មានពន្លឺនោះទេចាសហើយមកលូវនឹងគឺមានពន្លឺហើយចឹងសូមផ្តែលផ្តាំទៅកាន់កូនចៅអោយចេះតស៊ូរនៅក្នុងឆាកជីវិតរបស់យើងចឹងហាសពីព្រោះអីនឹងគឺលូវនឹងគឺយើងមានពន្លឺបិននឹងហើយសូមអោយកូនចៅនឹងបានខំប្រឹងដើម្បីនឹងរកចឹងទៅកុំអោយដើរផ្លូវណាដែលមិនល្អចឹងហាសចាសហើយសំរាប់ខ្ញុំគ្រាន់តែផ្តែលផ្តាំទៅកាន់កូនចៅរបស់ខ្ញុំនឹងបិននឹងចឹងហាសចាសហើយសូមអោយធ្វើនូវអំពើល្អហើយនៅពេលដែលច្បាប់ណាដែលគេបានធ្វើល្អចឹងហាសចាសសូមអោយពួកគាត់នឹងបានធ្វើតាមច្បាប់របស់គេចឹងហាសចាសគឺខ្ញុំសូមតែបិននឹងហាសចាស៕

ក៖ បាទហើយចឹងសំរាប់អ្នកមីងមានអ្វីសំរាប់បន្ថែមទៀតដែលរឺទេអ្នកមីង???

ខ៖ ចាសនិយាយទៅគឺអស់ហើយហេហេហេហេ៕

ក៖

បាទហើយចឹងអស់ហើយមែនដែលអ្នកមីងហេហេហេហេបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំអត់សួរមានអ្វីច្រើនទៀតនោះទេសំរាប់អ្នកមីងហើយក៏អរគុណច្រើនម្តងទៀតសំរាប់អ្នកមីងបាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំមានតែប៉ុននឹងសំរាប់អ្នកមីងហើយចឹងអរគុណច្រើនអ្នកមីងហើយខ្ញុំជំរាបលាម្តងទៀតអ្នកមីងបាទ៕